# មាឃបូជា
# វិសាខបូជា
# និង
# ពិធីពុទ្ធាភិសេក

គណៈកម្មការធម្មវិន័យ



ធម្មវិនយោ លោកេ បជ្ជោតោ

បណ្ណាគារយាយតា

ផ្ទះលេខ១7ផ្សារអូរឫស្សី

រក្សាសិទ្ធិហាមថតចម្លង

ព.ស. ២៥៣៣ គ.ស. ១៩៨៩

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# មាឃបូជា
# វិសាខបូជា
# និង
# ពិធីពុទ្ធាភិសេក

គណៈកម្មការធម្មវិន័យ



រៀបរៀងដោយ លោកតេ ប៊ុតឆ្លៃ។

បណ្ណាគារយាយតា

តូបលេខ១7ផ្សារអូរឫស្សី

រក្សាសិទ្ធិហាមថតចម្លង

ព.ស. ២៥៣៣ គ.ស. ១៩៨៩

# អារម្ភកថា

- អនុវត្តតាមស្មារតីគោលការណ៍ ១១ ខ របស់រណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជា ស្តីពិសិទ្ធិសេរីភាព ខាងជំនឿសាសនា ។

- យោងតាមសំណូមពរ ក្នុងសង្ឃសន្និបាតទូទាំងប្រទេស លើកទី ១ និងលើកទី ២ ស្នើសុំឱ្យបោះពុម្ពសៀវភៅធម៌នានា ។

- យោងតាមមាត្រា ៦ រដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា ចែងថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

- យោងតាមលិខិតរបស់គណៈលេខាធិការដ្ឋានបក្សប្រជាជនកម្ពុជាលេខ៦៦ ដ.ខ.ម.ប ចុះថ្ងៃទី ២២ មីនា ១៩៨៩ ឱ្យគណៈកម្មការបោះពុម្ពសៀវភៅធម៌វិន័យ ដែលមានស្រាប់ពីមុនឡើងវិញ ក្នុងនោះមានមាឃបូជាវិសាខបូជានិងពុទ្ធាភិសេកផងដែរ ដើម្បីបម្រើសំណូមពរពុទ្ធសាសនិកទូទៅ ។

គណៈកម្មការ រៀបចំបោះពុម្ពសៀវភៅធម៌-វិន័យព្រះពុទ្ធសាសនា ចាត់តាំងឡើង ដោយក្រុមប្រឹក្សាជាតិរណសិរ្ស លេខ ៣៥/៨៥ ក រ ស ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ១៩៨៥ បានប្រមូលអត្ថបទធម៌ផ្សេងៗ របស់លោកអ្នកប្រាជ្ញជំនាន់មុនមានសម្តេចព្រះសង្ឃរាជ ជោតញ្ញាណោ ( ជួន-ណាត ) ជាដើម ដែលទាក់ទងក្នុងពិធីគោរព មាឃបូជា-វិសាខបូជានិងពុទ្ធាភិសេក យកមកចងក្រងជាសៀវភៅមួយឈ្មោះថា "មាឃបូជាវិសាខបូជានិងពុទ្ធាភិសេក" ។

គណៈកម្មការ រង់ចាំជានិច្ច ទទួលការរិះគន់ស្ថាបនា ពីពួកពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន ។

# នមស្ការព្រះបរមសារីរិកធាតុ (១)

មាឃវស្សានិ សម្ពុទ្ធោ    ភគវា យោ តថាគតោ
សមសីត្យាយុកកាលេ    បរិនិព្វាយិ សោ មុនិ
តស្ស សារីរិកា ធាតុ    អម្ហាកំ បមុខេ ឋិតា
តថាគតោ ច សោ សត្ថា    ធរមានោ វ តិដ្ឋតិ
សក្ការេហាភិបូជេម    តំ នមស្សាម សាទរំ
សាធុ នោ ភគវា នាថោ    សព្វញ្ញូ សន្និធាយកោ
ឥមេ ឧលិន្ទសក្ការេ    អនុកម្បាយ គណ្ហតុ
ទីឃរត្តំ ហិតាយេវ    សុខាយម្ហាក សព្វទា ។

ព្រះតថាគត ភគវន្តមុនីអង្គណា ទ្រង់បានត្រាស់ហើយ (ឋិតនៅ) អស់ ៤៥ ឆ្នាំ, ព្រះតថាគតអង្គនោះ ព្រះអង្គជាមហាមុនី ទ្រង់បរិនិព្វានហើយ ក្នុងកាលដែលព្រះអង្គមានព្រះជន្មាយុ ៨០ គត់ (ឥឡូវ) ព្រះបរមសារីរិកធាតុនៃព្រះអង្គ មកប្រតិស្ឋានក្នុងទីចំពោះមុខ នៃយើងខ្ញុំព្រះអង្គ ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់គង់ព្រះធរមាន

---

១-វត្តដែលមានព្រះបរមសារីរិកធាតុ ក្នុងវេលាបុណ្យមាឃបូជា ឬវិសាខបូជាលោកអាចារ្យគួរនាំនមស្ការព្រះបរមសារីរិកធាតុ មុនការប្រកាសមាឃបូជា ឬវិសាខបូជា គឺលោកអាចារ្យត្រូវអានបាលីនេះ ព្រមទាំងសម្រាយផង មួយរយៈម្តងៗ ឱ្យពុទ្ធបរិស័ទថាតាមព្រមៗ គ្នា។ អត្ថបទនេះ សម្តេចព្រះសង្ឃរាជទ្រង់តែងឡើងក្នុងកាល ព.ស.២៥០១ គ.ស.១៩៥៨។

នៅឡើយ ស្តេចយាងមកក្នុងទីនេះ យើងខ្ញុំ សូមបូជាចំពោះព្រះអង្គ ដោយគ្រឿងសក្ការៈទាំងឡាយ សូមនមស្ការ ព្រះអង្គដោយគោរព. សូមព្រះភគវន្តមុនីសព្វញ្ញុពុទ្ធ បរមលោកនាថ ដែលតែងតែប្រោសប្រទាន សន្តិសុខដល់សត្វលោក ទ្រង់ព្រះមេត្តាប្រោស ទទួលនូវគ្រឿងសក្ការៈ ទាំងឡាយ របស់យើងខ្ញុំព្រះអង្គ ដែលជាសក្ការបូជារបស់អ្នកកំសត់ ទុគិតនេះ ដើម្បីអនុគ្រោះយើងខ្ញុំព្រះអង្គ ឱ្យបានហិតប្រយោជន៍ និងសេចក្តីសុខ សព្វកាលវេលា យូរអង្វែងរៀងទៅហោង ! ”។

( ក្រាបថ្វាយបង្គំ ៣ ដង )

## របៀបមាឃបូជា

សូមលោកអាចារ្យនាំឧបាសក-សិកា នមស្ការព្រះរតនត្រ័យតាមវិធី ត្រៃប្រណាមសង្ខេប ឬ ពិស្តារ ហើយសមាទានសីល ៨ រួចសឹមប្រកាស មាឃបូជាដូចតទៅនេះ :

## វិធីប្រកាសមាឃបូជា

( ត្រូវលោកអាចារ្យ អានមួយឃ្លាម្តង១ ឱ្យអ្នកទាំងអស់ថាតាមព្រម១ គ្នា)

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស**

**បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អានន្ទេន**

**នមស្សាមិ ។**

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង. ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស**
**បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ អាទរេន**
**នមស្សាមិ ។**

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយ ដោយប្រពៃ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះធម៌នោះ ជាធម៌ស្រោចស្រង់សត្វពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះធម៌នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**សុប្បដិបន្នោ វតស្ស ភគវតោ សោ សាវកសង្ឃោ**
**យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ**
**អាទរេន នមស្សាមិ ។**

ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខ ទាំងពួង, ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះ

លោកប្រតិបត្តិ ដោយប្រពៃពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

-(ក្រាបថ្វាយបង្គំម្តង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែមាឃ មានព្រះច័ន្ទពេញវង់ត្រូវនឹងថ្ងៃ នៃសាវកសន្និបាត របស់ព្រះសក្យមុនី អរហន្តសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង, សាវកសន្និបាតនោះ ប្រកបដោយអង្គ ៤ គឺ ថ្ងៃពេញបូណ៌មីខែមាឃ ព្រះច័ន្ទចរចូលក្នុងមាឃនក្ខត្តឫក្ស នេះជាអង្គទី១, ព្រះភិក្ខុសង្ឃ មានចំនួន ១.២៥០ គ្មានអ្នកណានិមន្ត ឬណាត់ពេលវេលាគ្នាសោះឡើយ ក៏ស្រាប់តែមកប្រជុំគ្នា ក្នុងសំណាក់នៃព្រះបរមសាស្តានាវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ក្រុងរាជគ្រឹះ មគធរដ្ឋ នៅវេលាថ្ងៃល្ងាច នេះជាអង្គទី ២, ព្រះភិក្ខុសង្ឃ ទាំង ១.២៥០ អង្គនោះ សុទ្ធតែជាឯហិភិក្ខុដូចគ្នាទាំងអស់ នេះជាអង្គទី ៣, ព្រះភិក្ខុសង្ឃ ទាំង ១.២៥០ អង្គនោះសុទ្ធតែជាខីណាស្រពទាំងអស់ នេះជាអង្គទី ៤, ព្រះសព្វញ្ញុពុទ្ធទ្រង់ត្រាស់សម្តែង នូវឱវាទបាតិមោក្ខក្នុងទីប្រជុំ នៃព្រះភិក្ខុសង្ឃនោះ ។ ការប្រជុំសាវ័កបែបនេះ ហៅថា **"ចតុរង្គសន្និបាត"** គឺការប្រជុំប្រកបដោយអង្គ ៤ ក្នុងពុទ្ធកាលនៃព្រះសក្យមុនី បរមគ្រូរបស់យើងមានតែម្តងប៉ុណ្ណោះ ។ មួយទៀត កាលដែលព្រះបរមសាស្តានៃយើងទ្រង់មានព្រះជន្ម បើគិតតាមឈ្មោះខែ នៅខ្វះ ៤ ខែ បើគិតតាមចំនួនថ្ងៃ

នៅខ្វះតែ ៨៨ ថ្ងៃទៀត នឹងគ្រប់ ៨០ ឆ្នាំគត់ ព្រះអង្គទ្រង់កំណត់ នូវព្រះជន្មាយុសង្ខារថា "ម្នាលភិក្ខុទាំងឡាយ គិតពីថ្ងៃនេះទៅ នៅខ្វះតែ ៤ ខែទៀតទេ តថាគតនឹងរលត់ខន្ធ ចូលកាន់បរិនិព្វាន" ។ ការកំណត់ព្រះជន្មាយុនេះ នៅថ្ងៃ ១៥ កើត ខែមាឃដែរ ។ តិថីនេះ ជាឧបលក្ខិតសម័យមួយដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជា ចំពោះ ព្រះសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះ អរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ ។

ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបគ្រឿងសក្ការបូជា មានទៀនធូប និងផ្កាជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ(១) គង់ជាប្រធាន ហាក់ដូចជា ព្រះ បរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំង- អស់គ្នា យើងខ្ញុំសូមថ្វាយ នូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មា- សម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យ ទាំងបី ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ

---

១-ត្រង់ចន្លោះនេះ បើមានព្រះសារីរិកធាតុ ត្រូវបញ្ចូលពាក្យថា "និងព្រះសារីរិកធាតុ" ផង ។

ទោះបីព្រះអង្គចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែង ទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ឋាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធិវិសេស ទុកជាតំណាងព្រះអង្គ ទ្រង់ព្រះគុណ របស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះសារីរិកធាតុ និងព្រះពុទ្ធរូប ស្នងព្រះអង្គ ក៏នៅមានប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្តា ទ្រង់ព្រះមេត្តា ទទួល នូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុង ទីនេះ ដើម្បីជាផលានិសង្ស ឱ្យយើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញ-ផល វិបុលសុខ និងសេចក្តីចម្រើន ដ៏ធំទូលាយ អស់កាលជាអង្វែងទៅហោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

ចប់ វិធីប្រកាសមាឃបូជា

◆◆◆◆◆

លុះចប់វិធីប្រកាសមាឃបូជាហើយ សូមព្រះសង្ឃទាំងអស់ នមស្ការព្រះរតនត្រ័យ តាមវិធីប្រែប្រណាម និងធម៌សម្រាប់ នមស្ការផ្សេងៗ ទៀត តាមដែលអាចសូធ្យបាន គ្រប់ព្រះអង្គ ។ តទៅសូមឱ្យភិក្ខុ ឬសាមណេរមានសំឡេងពីរោះ ដែលបានហាត់ហើយ សូធ្យ ២ អង្គ ១ នូវនមក្ការគាថា ដូចខាងចុងនេះ ហើយនិមន្តធម្មកថិកសម្តែងធម៌ទេសនា ។ លុះចប់ធម៌ទេសនា ហើយ ពុទ្ធបរិស័ទណា ចង់សូធ្យបទផ្សេងៗ ដែលស្របនឹងបុណ្យនេះ ក៏សូមសូធ្យទាល់តែភ្លឺទៅចុះ ។

(ចប់ របៀបមាឃបូជា)

# របៀបវិសាខបូជា

មុននឹងប្រកាសវិសាខបូជា សូមលោកអាចារ្យនាំឧបាសក-សិកា នមស្ការព្រះរតនត្រ័យ តាមវិធីត្រៃប្រណាមសង្ខេប ឬ ពិស្តារ ហើយសមាទានសីល ៨ រួចសឹមប្រកាស វិសាខបូជា ដូចតទៅនេះ :

## វិធីប្រកាសវិសាខបូជា

( ត្រូវពុទ្ធមាមកជនម្នាក់ អានមួយសង្កាត់ម្តង១ ឱ្យពុទ្ធមាមកជនទាំងអស់ ថាតាមព្រម១ គ្នា)

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។

**សម្មាសម្ពុទ្ធោ វត សោ ភគវា យោ សព្វទុក្ខស្ស បហានាយ ធម្មំ ទេសេតិ តំ សម្មាសម្ពុទ្ធំ អាទរេន នមស្សាម ។**

ព្រះភគវន្តមុនីអង្គណា ទ្រង់ត្រាស់សម្តែងនូវធម៌ ដើម្បីកម្ចាត់បង់នូវសេចក្តីទុក្ខទាំងពួង, ព្រះភគវន្តមុនីអង្គនោះ ជាព្រះសម្មាសម្ពុទ្ធពិតមែន យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធអង្គនោះ ដោយគោរព ។

( ក្រាបថ្វាយបង្គំម្តង)

**និយ្យានិកោ វត សោ ធម្មោ យោ សព្វទុក្ខស្ស បហានាយ ស្វាក្ខាតោ តេន ភគវតា តំ ធម្មំ**

**អាទរេន នមស្សាម ម**

ព្រះធម៌ណា ដែលព្រះភគវន្តមុនីអង្គនោះ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះធម៌នោះជាធម៌ស្រោចស្រង់សត្វពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះធម៌នោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

**សុប្បដិបន្នោ ចតស្ស ភគវតោ សោ សាវកសង្ឃោ**
**យោ សព្វទុក្ខស្ស បហានាយ បដិបន្នោ តំ សង្ឃំ**
**អាទរេន នមស្សាម ម**

ព្រះអរិយសង្ឃណា លោកប្រតិបត្តិ ដើម្បីកម្ចាត់បង់ នូវសេចក្តីទុក្ខទាំងពួង, ព្រះអរិយសង្ឃនោះ ជាសង្ឃសាវ័ក នៃព្រះភគវន្តមុនីអង្គនោះលោកប្រតិបត្តិ ដោយប្រពៃពិតមែន, យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

ថ្ងៃនេះ ជាតិថីពេញបូណ៌មី នៃខែវិសាខ មានព្រះច័ន្ទពេញវង់ត្រូវនឹងថ្ងៃ ដែលព្រះសក្យមុនី សម្មាសម្ពុទ្ធ ជាបរមគ្រូ ទ្រង់ប្រសូតទ្រង់បានត្រាស់ ជាព្រះសព្វញ្ញុពុទ្ធ ប្រាកដឡើងក្នុងលោក និងថ្ងៃដែលទ្រង់រលត់ខ័ន្ធ ចូលកាន់បរិនិព្វាន, តិថីនេះ ជាឧបលក្ខិតសម័យមួយ

ដ៏ឧត្តម ក្នុងព្រះពុទ្ធសាសនា គឺជាថ្ងៃសម្រាប់ពុទ្ធមាមកជន ទាំងបព្វជិត ទាំងគ្រហស្ថ ប្រជុំគ្នាធ្វើសក្ការបូជា ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ ជាបរមពុទ្ធោវាទ និងព្រះអរិយសង្ឃ ជាសាវ័ករបស់ព្រះអង្គ ឥឡូវនេះ យើងទាំងអស់គ្នា ជាពុទ្ធសាសនិកជន បានមកប្រជុំគ្នា បានរៀបគ្រឿងសក្ការបូជា មានទៀនធូបនិងផ្កាជាដើម ក្នុងទីនេះ ដែលមានព្រះពុទ្ធរូបស្នងព្រះអង្គ (១) គង់ជាប្រធាន ហាក់ដូចជា ព្រះបរមសាស្តាអង្គនោះ ទ្រង់ស្តេចមកគង់ ក្នុងទីចំពោះមុខ នៃយើងទាំងអស់គ្នា. យើងខ្ញុំសូមថ្វាយ នូវគ្រឿងសក្ការបូជាទាំងនេះ ចំពោះព្រះសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ រតនត្រ័យទាំង ៣ ដោយសេចក្តីគោរព ។

បពិត្រព្រះសក្យមុនីបរមគ្រូ ព្រះអង្គជាបូជារហបុគ្គល របស់ទេវតា និងមនុស្សក្នុងលោក ឥតមានបុគ្គលណាមួយ ត្រឹមស្មើនឹងព្រះអង្គឡើយ ទោះបីព្រះអង្គ ទ្រង់ចូលបរិនិព្វាន បាត់ព្រះរូបព្រះកាយ អស់កាលយូរអង្វែងទៅហើយ ក៏ពិតមែន ប៉ុន្តែទ្រង់បានប្រតិស្ឋាន ព្រះវិសុទ្ធោវាទ គឺព្រះធម៌វិន័យ ដ៏បរិសុទ្ធវិសេស ទុកជាតំណាងព្រះអង្គ ទ្រង់ព្រះគុណរបស់ព្រះអង្គ ក៏នៅមានប្រាកដ ទាំងព្រះបរមសារីរិកធាតុ និងព្រះពុទ្ធរូប

---

១-ត្រង់ចន្លោះនេះ បើមានព្រះសារីរិកធាតុ. ត្រូវបញ្ចូលពាក្យថា "និងព្រះសារីរិកធាតុ" ផង ។

ស្អងព្រះអង្គ ក៏នៅមានប្រាកដដែរ សូមព្រះដ៏មានបុណ្យ ជាបរមសាស្តា ទ្រង់ព្រះមេត្តាប្រោសទទួល នូវគ្រឿងសក្ការបូជា របស់យើងខ្ញុំព្រះអង្គ ដែលរៀបចំថ្វាយក្នុងទីនេះ ដើម្បីជាផលានិសង្ស ឱ្យយើងខ្ញុំព្រះអង្គ បានប្រកបដោយឥដ្ឋមនុញ្ញផល វិបុលសុខ និងសេចក្ដីចម្រើន ដ៏ធំទូលាយ អស់កាលជាអង្វែងទៅបោង ។

(ក្រាបថ្វាយបង្គំ ៣ ដង)

ចប់ វិធីប្រកាសវិសាខបូជា

លុះចប់វិធីប្រកាសវិសាខបូជានេះហើយ សូមព្រះសង្ឃទាំងអស់នមស្ការ ព្រះរតនត្រ័យតាមវិធីត្រៃប្រណាម និងធម៌សម្រាប់ នមស្ការផ្សេងៗ ទៀត តាម ដែលអាចសូធ្យបានគ្រប់ព្រះអង្គ ។ តទៅ សូមភិក្ខុ ឬសាមណេរមានសំឡេង ពីរោះ ដែលបានហាត់ហើយ សូធ្យ ២ អង្គម្ដងៗ នូវ **នមស្ការគាថា** ដូចមាន ខាងចុងនេះ ហើយនិមន្តធម្មកថិកសម្ដែងធម៌ទេសនា។ លុះចប់ ធម៌ទេសនាហើយ ពុទ្ធបរិស័ទណាចេះសូធ្យបទផ្សេងៗ ដែលស្របនឹងបុណ្យនេះ ដូចធម៌បទក្នុង **គោតមប្បវត្តិ** ជាដើម ក៏សូមសូធ្យឱ្យទាល់តែទើសភ្លឺទៅចុះ ។ ព្រោះក្នុងវិធី បុណ្យនេះ ពុទ្ធបរិស័ទគួរតែកម្សាន្ត តាមផ្លូវធម៌ឱ្យទាល់តែភ្លឺ កុំឱ្យខុសរបៀបពី បុរាណមកផង កុំឱ្យចាញ់ប្រៀបពួកកាតូលិក ដែលគេធ្វើបុណ្យណូអែលផង។

(ចប់របៀបវិសាខបូជា)

# នមក្ការគាថា

## មហានាគនមក្ការគាថា(១)

គាថានមស្ការចំពោះព្រះមហានាគ

បឋ្យាវត្តឆន្ទ

**សេដ្ឋោ តថាគតោ លោកេ ពុទ្ធនាគោតិ វិស្សុតោ**
**នាគេន ទេសិតោ ធម្មោ និយ្យានិកោតិ សញ្ញិតោ**
**តស្សាបិ សាវកោ សង្ឃោ សន្តិន្ទ្រិយោ អនាសវោ**
**នាគិ ឆាបកំ អាគុំ តស្មា នាគោតិ វុច្ចរេ ៕**

កាព្យបឋ្យាវត្ត ( កុំច្រឡំហៅកាព្យពាក្យ ៨ )

ព្រះតថាគត វិសុទ្ធក្នុងលោក ព្រះអង្គមានជោគ លើសលោកទាំងបី
ព្រះនាមពុទ្ធនាគ ជាពាក្យបាលី អស់ជនប្រុសស្រី គប្បីដឹងច្បាស់ ។
ថាជាព្រះនាម ព្រះពុទ្ធជាម្ចាស់ ប្រសើរពេកណាស់ លើសមនុស្សទេព្តា
ព្រះធម៌ដែលព្រះ- ពុទ្ធនាគទេសនា ប្រោសអស់ទេវតា មនុស្សសត្វ-
ទាំងឡាយ ។

---

១-មហានាគនមក្ការគាថានេះ និងអដ្ឋវីសសម្ពុទ្ធនមក្ការគាថាខាងចុងបន្ទាប់គ្នានេះ គឺសម្តេចព្រះមហាសុមេធាធិបតី ( ជ.ណ. ជោតញ្ញាណោ ) ទ្រង់ប្រែជាសម្រាយពាក្យរាយតាំងពី ព.ស. ២៤៧៦ គ.ស. ១៩៣៣ លោក អ៊ុង ខេង ប្រែជាកាព្យបោះពុម្ពជាសៀវភៅ ១ ឈ្មោះ នមក្ការគាថា តាំងពី ព.ស. ២៤៨៨ គ.ស. ១៩៤៥ ។

ជាធម៌ស្រង់សត្វ ឱ្យផុតអបាយ អ្នកប្រាជ្ញទាំងឡាយ លោកបានជ្រាបច្បាស់
ព្រះអរិយសង្ឃ សាវ័កច្រើនណាស់ ជាសង្ឃនៃព្រះពុទ្ធនាគជាធំ ។
សង្រួមឥន្ទ្រិយ ស្រគត់ស្រគំ កិលេសតូចធំ ក្សិណក្ស័យអស់ហើយ លោក
ឈប់ស្រឡះ គ្មានប៉ះពាល់ឡើយ ព្រះសង្ឃនេះហើយ ដែលទ្រង់ប្រទាន ។
នាមថានាគោ ទុកជាប្រធាន ព្រោះលោកពុំមាន ធម៌ដ៏លាមក លោក
ឈប់ស្រឡះ លែងធ្វើអាក្រក់ ព្រោះលោកនាយក ព្រះពុទ្ធនាគនោះ ។
ទ្រង់ប្រោសប្រទាន នាគោជាឈ្មោះ ជាពាក្យពីរោះ ចំពោះពុទ្ធដីកា
ដោយមានគម្ពីរ ព្រះមុនីទេសនា ប្រារព្ធនឹងកា- ឡុទាយិនោះ ។

**វន្ទេហំ ពុទ្ធនាគញ្ច ធម្មំ នាគេន ទេសិតំ**
**នាគស្សារិយសង្ឃញ្ច មហានាគន្តិ វិស្សុតំ**
**ពុទ្ធនាគានុភាវេន ឧប្បន្នា ចេ ឧបទ្ទវា**
**រោគា ចេវន្តរាយា ច វិនស្សន្តុ អសេសតោ ៥**

យើងខ្ញុំព្រះអង្គ សូមថ្វាយបង្គំ ចំពោះព្រះបរម ព្រះពុទ្ធនាគផង
ចំពោះព្រះធម៌ ប្រសើរកន្លង ដែលព្រះច្បាស់ច្បង ពុទ្ធនាគសម្តែង ។
និងព្រះអរិយសង្ឃ ព្រមទាំងគម្តែង មាននាមជាក់ស្តែង ហៅមហានាគោ
ជាទីសាវ័ក មានថ្នាក់សេដ្ឋោ ព្រះពុទ្ធនាគោ ប្រទានទុកមក ។
តេជះវត្តត្រៃ ថ្លាថ្លៃពន្លក យើងខ្ញុំសូមជ្រក ក្រោមម្លប់សាខា
មានព្រះពុទ្ធនាគ ជាដើមថ្លៃថ្លា ទោះរោគភយា ឧបទ្រពអន្តរាយ ។

ដែលកើតមានឡើង ឱ្យប៉ើងខ្ចាត់ខ្ចាយ សូមឱ្យរលាយ វិនាសបាត់ទៅ
បើពុំទាន់មាន ឱ្យខាននៅក្រៅ ចៀសចេញឆ្ងាយទៅ កុំនៅវៀងអាយ ។
សូមសុខសព្វកាល ត្រអាលសប្បាយ សម្បត្តិទាំងឡាយ សម្បូណ៌ឥតខ្ចះ ។

# អដ្ឋវីសសម្ពុទ្ធនមក្ការគាថា

គាថានមស្ការចំពោះព្រះសម្ពុទ្ធ ២៨ ព្រះអង្គ

វន្ទេ តណ្ហង្ករំ ពុទ្ធំ　　វន្ទេ មេធង្ករំ មុនឹ
សរណង្ករំ មុនឹ វន្ទេ　　ទីបង្ករំ ជិនំ នមេ
វន្ទេ កោណ្ឌញ្ញសត្ថារំ　　វន្ទេ មង្គលនាយកំ
វន្ទេ សុមនសម្ពុទ្ធំ　　វន្ទេ រេវតនាយកំ
វន្ទេ សោភិតសម្ពុទ្ធំ　　អនោមទស្សឹ មុនឹ នមេ
វន្ទេ បទុមសម្ពុទ្ធំ　　វន្ទេ នារទនាយកំ
បទុមុត្តរំ មុនឹ វន្ទេ　　វន្ទេ សុមេធនាយកំ
វន្ទេ សុជាតសម្ពុទ្ធំ　　បិយទស្សឹ មុនឹ នមេ
អត្ថទស្សឹ មុនឹ វន្ទេ　　ធម្មទស្សឹ ជិនំ នមេ
វន្ទេ សិទ្ធត្ថសត្ថារំ　　វន្ទេ តិស្សមហាមុនឹ
វន្ទេ ផុស្សមហាវីរំ　　វន្ទេ វិបស្សិនាយកំ
សិខឹ មហាមុនឹ វន្ទេ　　វន្ទេ វេស្សភុនាយកំ
កកុសន្ធំ មុនឹ វន្ទេ　　វន្ទេ កោនាគមនំ ជិនំ
កស្សបំ សុគតំ វន្ទេ　　វន្ទេ គោតមនាយកំ
អដ្ឋវីសតិមេ ពុទ្ធា　　និព្វានាមតទាយកា

## នមោ តេ សិរសា និច្ចំ តេ មំ រក្ខន្តុ សព្វទា ខ

កាព្យបឋ្យាវដ្ត (កុំច្រឡំហៅកាព្យពាក្យ ៨)

ខ្ញុំសូមបង្គំ ព្រះបរមសម្ពុទ្ធ មាននាមប្រាកដ ព្រះតណ្ហង្ករ
ខ្ញុំសូមបង្គំ ព្រះបរមបវរ ព្រះមេធង្ករ ជាសម្ពុទ្ធា ។
សូមក្រាបបង្គំ ប្រណម្យវន្ទា នូវព្រះភគវា ព្រះសរណង្ករ
សូមថ្វាយបង្គំ ព្រះទីបង្ករ មានញាណបវរ បារមីពោរពេញ ។
សូមថ្វាយបង្គំ នូវព្រះកោណ្ឌញ្ញ ព្រះអង្គបំពេញ ធម៌ជាកុសល
ខ្ញុំសូមបង្គំ នូវព្រះទសពល ព្រះនាមមង្គល ជាសម្ពុទ្ធៈ ។
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ព្រះនាមសុមនៈ សម្មាសម្ពុទ្ធ
ខ្ញុំសូមបង្គំ ព្រះបរមសុគត ព្រះនាមប្រាកដ ព្រះរេវតៈ ។
ខ្ញុំសូមបង្គំ ព្រះបរមពុទ្ធៈ មានញាណសោភៈ ព្រះនាមសោភិត
ខ្ញុំសូមបង្គំ ប្រណម្យប្រណិត ឆ្ពោះព្រះវិជិត អនោមទស្សី ។
ខ្ញុំសូមក្រាបថ្វាយ ឱនកាយសិរសី ចំពោះព្រះមុនី ព្រះនាមបទុម
ខ្ញុំសូមឱនកាយ ថ្វាត់ថ្វាយបង្គំ ចំពោះព្រះបរម ព្រះនាមនារទៈ ។
សូមថ្វាយបង្គំ ព្រះបទុមុត្តរៈ មានញាណសោភៈ វរពុទ្ធា
ខ្ញុំសូមបង្គំ នូវព្រះភគវា ទ្រង់ព្រះនាមា សមេធសម្ពុទ្ធ ។
ខ្ញុំសូមបង្គំ ប្រណម្យក្រាបលុត ឆ្ពោះព្រះសម្ពុទ្ធ ព្រះនាមសុជាត
ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ ឆ្ពោះព្រះមុនីនាថ បិយទស្សី ។

ខ្ញុំសូមបង្គំ ឆ្ពោះព្រះជិនស្រី អត្ថទស្សី បារមីខ្ពង់ខ្ពស់
ខ្ញុំសូមបង្គំ ឆ្ពោះព្រះទ្រង់យស ព្រះនាមចំពោះ ធម្មទស្សី ។
ខ្ញុំសូមបង្អោន លំទោនសិរសី បង្គំជិនស្រី ព្រះនាមសិទ្ធត្ថ
ខ្ញុំសូមបង្គំ នូវព្រះមុនីរតន៍ ព្រះនាមប្រាកដ តិស្សៈសាស្តា ។
ខ្ញុំសូមបង្គំ នូវព្រះសម្មា- សម្ពុទ្ធនាមថា ផុស្សៈមុនី
ខ្ញុំសូមបង្គំ ប្រណម្យអញ្ជលី ឆ្ពោះព្រះមុនី ព្រះនាមវិបស្សី ។
សូមថ្វាយបង្គំ ព្រះបរមជិនស្រី ព្រះនាមសិខី សពិជ្រពុទ្ធា
ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា ឆ្ពោះព្រះភគវា ព្រះនាមវេស្សភូ ។
ខ្ញុំសូមបង្គំ លើកបាត្ថទាំងគូ ឆ្ពោះព្រះជាគ្រូ នាមកកុសន្ធៈ
ខ្ញុំសូមបង្គំ ប្រណម្យគារវៈ ឆ្ពោះព្រះពុទ្ធៈ កោនាគមនោ ។
ខ្ញុំសូមឱនកាយ វាចាមនោ បង្គំពុទ្ធោ ព្រះនាមកស្សបៈ
ខ្ញុំសូមលំទោន បង្អោនសិរៈ ឆ្ពោះព្រះសមណៈ ព្រះនាមគោតម ។
គម្រប់ម្ភៃ-ប្រាំបីព្រះបរម សម្ពុទ្ធជាធំ កំពូលលោកា
ទូទាំងត្រៃភព ជាម្លប់សាខា មនុស្សសត្វទេវតា មារព្រហ្មទាំងឡាយ ។
ដែលបានចូលជ្រក ក្រោមម្លប់ព្រះឆាយ បានសុខសប្បាយ គ្រប់រូបរាល់គ្នា
បានទៅសោយសុខ ក្នុងឋានសួគ៌ា ឬឋានព្រហ្មា និងព្រះនិព្វាន ។
**ដោយ**បុណ្យបារមី នៃព្រះទ្រង់ញាណ ព្រះធម៌ប្រធាន ជាយាននាំសត្វ
**តេជះ**យើងខ្ញុំ ប្រណម្យថ្វាយថ្វាត់ នូវព្រះពុទ្ធរតន៍ គ្រប់ៗ ព្រះអង្គ ។

ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ សាវ័កគ្រប់អង្គ ម្ភៃប្រាំបី
សូមអានុភាព ពីព្រះជិនស្រី ម្ភៃប្រាំបី ព្រះអង្គនោះឯង ។
ព្រមទាំងព្រះធម៌ ព្រះអង្គសម្តែង ទាំងព្រះតម្កែង សង្ឃជាសាវ័ក
សូមសុខចម្រើន កើតឡើងតាមថ្នាក់ កុំឱ្យមានអាក់ អន់អាប់ឡើយណា ។
សូមឱ្យខ្ញុំបាន ដល់ឋានទេវតា ដូចក្តីប្រាថ្នា កុំបីឃ្លៀងឃ្លាត
មានព្រះនិព្វាន ជាអវសានជាតិ កុំឱ្យខ្ញុំឃ្លាត បច្ចយោ ហោតុ ! ។

✲ ✲ ✲ ✲ ✲

# ពុទ្ធបាទនមក្ការគាថា (១)

គាថានមស្ការស្នាមព្រះបាទព្រះពុទ្ធ

**វន្ទាមិ ពុទ្ធំ ភវបារតិណ្ណំ**
**តិលោកកេតុំ តិភវេកនាថំ**
**យោ លោកសេដ្ឋោ សកលំ កិលេសំ**
**ឆេត្វាន ពោធេសិ ជនំ អនន្តំ ។**

ព្រះសព្វញ្ញុពុទ្ធ វិសេសផុតត្រៃលោកា គ្មានមនុស្សឬទេវតា ព្រហ្មាណាប្រៀបបាន ។ កម្ចាត់នូវកិលេស គ្មានឱ្យសេសនៅសល់ខាន ញ៉ាំងជនទាំងប៉ុន្មាន ជាអនន្តឱ្យត្រាស់ដឹង ។

ខ្ញុំសូមថ្វាយបង្គំ នូវព្រះបរមជាទីពឹង ព្រះអង្គឆ្លងផុតស្ទឹង បានដល់ច្រាំងនៃភពហើយ ។ ព្រះអង្គជាទង់ជ័យ ធំត្រៃឈៃបង្ហាញត្រើយ តែមួយព្រះអង្គហើយ ជាទីពឹងក្នុងត្រៃភព ។ មារព្រហ្មទាំងទេព្តា និងមនុស្សតែងគោរព ចូលជ្រកក្រោមព្រះម្លប់ ពោធិញ្ញាណបានសុខា ។

**យំ នម្មទាយ នទិយា បុលិនេ ច តីរេ**
**យំ សច្ចពន្ធគិរិកេ សុមនាចលគ្គេ**
**យំ តត្ថ យោនកបុរេ មុនិនោ ច បាទំ**

---

១-ពុទ្ធបាទនមក្ការគាថា និងធាតុចេតិយនមក្ការគាថា បន្ទាប់ត្តាខាងមុខនេះ គឺសម្តេចព្រះពោធិវង្ស ហួត តាត បានប្រែជាសម្រាយពាក្យរាយ បោះពុម្ពជាក់ខាងចុងសៀវភៅ សត្តបរិត្ត តាំងពី ព.ស. ២៤៧៧ លោក អ៊ឹង ខេង តែងជាកាព្យ ពី ព.ស. ២៤៨៩ ។

**តំ បាទលញ្ឆនមហំ សិរសា នមាមិ ។**

សូមថ្វាយបង្គំ ទសករប្រណម្យ ឆ្ពោះត្រង់ស្នាមព្រះបាទា.
ដែលព្រះមានជោគ ទ្រង់ព្រះមេត្តា ជាន់ទុកឱ្យជាស្ថានថ្លៃ ។
បាទមួយនៅនា ស្ទឹងនម្មទា ត្រង់ឆ្នេរខ្សាច់ប្រសើរក្រៃ.
បាទមួយទ្រង់ជាន់ ទុកនៅព្នំ- ដ៏ភ្នំគិរីសច្ចព័ន្ធ ។
បាទមួយនៅភ្នំ សុមនកូដ រហូតកំពូលដ៏សោភ័ណ.
ព្រះបាទមួយទៀត ព្រះទ្រង់ជាន់ ទុកនៅនាយោនកបុរី ។
ខ្ញុំសូមបន្ទន់ កាយវាចា និងចិត្តជ្រះថ្លាឱនសិរសី.
បង្គំព្រះបាទ ព្រះជិនស្រី សូមសុខសួស្តីគ្រប់វេលា ។

**សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ**
**យោនកបុរេ នម្មទាយ នទិយា**
**បញ្ចបាទវរំ ឋានំ អហំ វន្ទាមិ ទូរតោ ។**

ខ្ញុំសូមនមស្ការ អំពីចម្ងាយ នូវឋានទាំងឡាយ ដែលមានព្រះបាទ
ទាំងប្រាំកន្លែង ដែលព្រះមុនីនាថ ទ្រង់ឈានព្រះបាទ លើកំពូលភ្នំ ។
សុវណ្ណមាលិក មួយនោះជាធំ មួយនៅលើភ្នំ សុវណ្ណបពិត
មួយនៅលើភ្នំ សុមនកូដប្រាកដ មួយនៅរាជរដ្ឋ យោនកបុរី ។
មួយនៅក្បែរស្ទឹង នម្មទាជលធិ ទាំងប្រាំនាទី ដែលទ្រង់ប្រទាន
ទុកឱ្យសព្វសត្វ ប្រតិបត្តិជាស្ថាន ដែលព្រះទ្រង់ញាណ ប្រទានទុកឱ្យ ។

# ធាតុចេតិយនមក្ការគាថា

គាថានមស្ការព្រះចេតិយបញ្ចុះធាតុព្រះអង្គ

**មហាគោតមសម្ពុទ្ធោ   កុសិនារាយ និព្វុតោ**
**ធាតុវិត្ថារតំ កត្វា   តេសុ តេសុ វិសេសតោ**

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ   សារីរិកធាតុ ព្រះមហាគោតម
ដែលទ្រង់និព្វាន ក្រោមសាលព្រឹក្សធំ ជិតបុរីរម្យ ក្រុងកុសិនារា ។
កិរិយាផ្សាយនូវ ព្រះធាតុនានា   ផ្សេង១ ពីគ្នា ក្នុងទីទាំងឡាយ
ខ្ញុំសូមបង្គំ ប្រណម្យក្រាបថ្វាយ   ព្រះធាតុទាំងឡាយ គ្រប់ទីនោះ១ ។

**ឧណ្ហីសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច សត្តមា**
**អសម្ភិន្នាវ តា សត្ត   សេសា ភិន្នា វ ធាតុយោ ។**

ព្រះសារីរិកធាតុ ល្អស្អាតទាំងនោះ   ដែលមិនបែកសោះ ប្រាំពីរព្រះអង្គ ។
គឺព្រះឧណ្ហី- សះធាតុបញ្ចូង(១)   មានមួយព្រះអង្គ នៅគង់ល្អស្អាត ។
និងព្រះទាឋា(២) សារីរិកធាតុ   ទាំង៤អង្គស្អាត គ្មានឃ្លាតបែកចេញ
ព្រះអក្ខកធាតុ(៣) នៅស្អាតពេញលេញ គ្មានបែកបាក់ចេញ ទាំងពីរព្រះអង្គ
ព្រះសារីរិកធាតុ ភ្លឺស្អាតត្រចង់   ប្រាំពីរព្រះអង្គគង់នៅទាំងអស់
ព្រះសារីរិកធាតុ ដ៏សេសពីនោះ   បែកចេញចំពោះ បំណែកធំតូច ។

**មហន្តា បញ្ចនាឡិ ច   មជ្ឈិមា ច ន នាឡិយោ**

---

១-ឆ្អឹងថ្ងាស ។ ២-ព្រះចង្កូមកែវ ។ ៣- ឆ្អឹងដងកាំបិត ។

**ខុទ្ទកា បញ្ចនាឡិ ច សម្ភិន្នា តវធមតា ឬ**

ព្រះបរមធាតុ មុនីនាថសាស្តា ដែលបែកចេញជា បំណែកតូចធំ
លោកបានពោលទុក ថាមានទំហំ មានតូចមានធំ មានខ្នាតកណ្តាល ។
ព្រះធាតុខ្នាតធំ ចំនួនប្រាំនាឡិ ព្រះធាតុកណ្តាល ប្រាំមួយនាឡិគត់
ព្រះធាតុខ្នាតតូច ប្រាំនាឡិប្រាកដ តាមលោកកំណត់ បីយ៉ាងដូច្នេះ ។

**មហន្តា តិន្នមុគ្គា ច មជ្ឈិមា តិន្នតណ្ឌុលា**
**ខុទ្ទកា សាសបមត្តា ឯវំ ធាតុប្បមាណិកា**

ឯព្រះបរមធាតុ មានខ្នាតបីយ៉ាង លោកបានពោលអាង ទុកជាលំដាប់
ព្រះធាតុខ្នាតធំ ទំហំប៉ុនគ្រាប់ សណ្តែកបាយកាប់ កាត់មួយកំណាត់
ព្រះធាតុខ្នាតកណ្តាល ដូចកាលគេកាត់ ប៉ុនមួយកំណាត់ នៃគ្រាប់អង្ករ
ព្រះធាតុខ្នាតតូច ល្អិតល្អបវរ លោកបានព្យាករណ៍ ថាប៉ុនគ្រាប់ស្ពៃ ។

**មហន្តា សុវណ្ណវណ្ណា មជ្ឈិមា ផលិកប្បភា**
**ខុទ្ទកា ពកុលវណ្ណា តាបិ វន្ទាមិ ធាតុយោ**

ព្រះសារីរិកធាតុ នៃព្រះភគវា មានពណ៌ផ្សេងគ្នា ទាំងបីវិលាស
ព្រះធាតុខ្នាតធំ មានពណ៌ដូចមាស ពន្លឺឱភាស វិសេសពេកក្តាត់ ។
ព្រះធាតុកណ្តាល វិលាសដូចរ័តន៍ កែវផ្លិកប្រាកដ ស្មើរចាប់ច្រឡំ
ព្រះធាតុខ្នាតតូច ដូចផ្កាពុលសម ពណ៌សស្រគាំ ពុំគួរជឿងឆ្ងល់ ។
ខ្ញុំសូមបង្គំ ប្រណម្យទៅដល់ ព្រះធាតុមង្គល ទាំងឡាយនោះផង

តេជះខ្ញុំថ្វាយ ឱនកាយវាបវង    វាចាចិត្តផង សូមឆ្លងទៅដល់ ។
ទីព្រះបរមធាតុ មុនីនាថទសពល    សូមជាមង្គល សុខសព្វវេលា
សូមឱ្យខ្ញុំបាន ដល់ឋានសួគ៌ា    រហូតដល់នា ព្រះនិព្វានហោង ។

**ឯកោ ថូបោ រាជគហេ    ឯកោ វេសាលិយា អហុ**
**ឯកោ កបិលវត្ថុស្មឹ    ឯកោ ច អលកប្បកេ**
**ឯកោ ច រាមគាមស្មឹ    ឯកោ ច វេឋទីបកេ**
**ឯកោ បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ**

ព្រះសថូបមួយបាន ប្រតិស្ឋាននា    រាជគ្រឹះភារា មហាបុរី
មួយប្រតិស្ឋាន ក្រុងវេសាលី    មួយនៅបុរី កបិលព័ស្តុសក្កៈ ។
ព្រះសថូបមួយនៅ អល្លកប្បកៈ    ព្រះសថូបសោភៈ មួយនៅរាមគ្រាម
មួយនៅវេដ- ទីបកៈដោយនាម    ពួកក្សត្រនិងព្រាហ្មណ៍ ទុកជាសរណៈ ។
មួយនៅនាក្រុង បាវេយ្យកៈ    នៅក្នុងមល្លៈ រដ្ឋជនបទ
ព្រះសថូបមួយមាន ទីឋានប្រាកដ    នៅក្នុងរាជរដ្ឋ កុសិនារា ។

**ឯតេ សារីរិកា ថូបា    ជម្ពុទីបេ បតិដ្ឋិតា**
**បូជិតា នរទេវេហិ    អហំ វន្ទាមិ ធាតុយោ**

ព្រះសថូបទាំងឡាយ ទាំងប្រាំបីនោះ ជាទីបញ្ចុះ ព្រះសារីរិកធាតុ
ក្នុងជម្ពូទ្វីប ខ្ញុំសូមអភិវាទ    នូវព្រះបរមធាតុ ទាំងឡាយទាំងនោះ
ក្នុងព្រះសថូប ប្រាំបីអង្គស្មោះ    ដែលពួកសប្បុរស លោកតែងបូជា

ខ្ញុំសូមបង្គំ ប្រណម្យវន្ទា ទាំងមនុស្សទេវា បូជាសព្វកាល ។

**ឯកា ទាឋា តិទសបុរេ ឯកានាគបុរេ អហុ**
**ឯកា គន្ធារវិសយេ ឯកា សីហឡទីបកេ**

ព្រះទាឋាធាតុ មុនិនាថមួយអង្គ[១] ប្រតិស្ឋានត្រង់ ក្នុងត្រៃត្រឹង្សា
ព្រះទាឋាធាតុ មួយអង្គថ្លៃថ្លា ប្រតិស្ឋាននា ពិភពនាគនាយ ។
ព្រះទាឋាធាតុ មួយអង្គព្រោងព្រាយ ឋិតនគរនាយ គន្ធាររដ្ឋ
ព្រះទាឋាធាតុ មួយអង្គប្រាកដ ឋិតនៅរាជរដ្ឋ សីហឡទ្វីប ។

**ឥមា ចតុស្សុ ឋានេសុ សត្ថុ ទាឋា បតិដ្ឋិតា**
**បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋាធាតុ ទាំងឡាយឯណា ដែលព្រះសាស្ដា ទ្រង់ប្រតិស្ឋាន
ទាំងបួនកន្លែង នោះឯងមែនមាន ទ្រង់ទុកប្រទាន ឱ្យមនុស្សទេព្តា ។
ជាទីគោរព ប្រតិបត្តិបូជា ខ្ញុំសូមវន្ទា ក្រាបថ្វាយបង្គំ
អំពីចម្ងាយ ឱនកាយប្រណម្យ ចំពោះព្រះបរ- មធាតុនោះឯង ។

**ឧទ្ធំ ទក្ខិណទាឋា ច តាវតឹសេ បតិដ្ឋិតា**
**អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា**
**វាមទាឋា ច ឧទ្ធម្បិ គន្ធាររដ្ឋេ បតិដ្ឋិតា**
**វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា**

---

១-ព្រះចង្កូមកែវ ។

**បូជិតា នរទេវេហិ　　អហំ វន្ទាមិ ធាតុយោ**

ព្រះទាឋាធាតុ ខាងលើខាងស្តាំ　　ព្រះឥន្ទនាំ ទៅត្រៃត្រឹង្សា
ព្រះទាឋាស្តាំ ខាងក្រោមសោភា　　ប្រតិស្ឋាននា សីហឡបុរី ។
ព្រះទាឋាឆ្វេង ខាងលើពិសី　　នៅនាបុរី ក្នុងដែនគន្ធារ
ទាឋាឆ្វេងក្រោម នៃព្រះឈ្មោះមារ　　នៅក្នុងភារា ពិភពនាគនោះ ។
ខ្ញុំព្រះករុណា វន្ទាចំពោះ　　នូវព្រះធ ]តុនោះ គ្រប់ទីទាំងឡាយ
ដែលមនុស្សទេព្តា តែងបូជាថ្វាយ　　ព្រះធាតុទាំងឡាយ ក្នុងទីនោះៗ ។

**ព្រហ្មលោកេ ទុស្សធាតុ　　ទាឋអក្ខធាតុយោ**

**សព្វេ ព្រហ្មាភិបូជេន្តិ　　ធុបំ ទ្វាទសយោជនំ**

ព្រះទុស្សធាតុ មុនីនាថឧត្តម(១)　　ដែលព្រះមហាព្រហ្ម ឈ្មោះឃដិការ
ទទួលយកពី ព្រះសាស្តាចារ្យ　　ទៅទុកនមស្ការ ក្នុងឋានព្រហ្មលោក ។
និងអក្ខក័(២) ធាតុឆ្វេង នៃព្រះមានជោគ នៅក្នុងព្រហ្មលោក ទាំងពីរព្រះអង្គ
មានព្រះសថូប កំពស់ខ្ពង់ខ្ពស់　　ដប់ពីរយោជន៍លង់ បញ្ចុះព្រះធាតុ ។
ខ្ញុំសូមបង្គំ ព្រះបរមលោកនាថ　　ចំពោះព្រះធាតុ នៅព្រ  ្មលោកនាយ ។

**តាវតឹសម្ហិ ទេវានំ　　ចូឡាមណិម្ហិ កេសកំ**

**សព្វេ ទេវាភិបូជេន្តិ　　បសន្នា ពុទ្ធសាសនេ**

---

១-ព្រះទុស្សធាតុ គឺព្រះពស្ត្រដែលព្រះអង្គផ្លាស់ចេញ ហើយទ្រង់សំពត់កាសាវៈ ។

២-ត្រូវអានថា អ័ក.ខ:ធាតុ ។

**បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ**

ទេវតាទាំងឡាយ ជាអ្នកជ្រះថ្លា  ក្នុងពុទ្ធសាសនា បូជាចំពោះ
នូវព្រះកេសធាតុ ព្រះបរមទ្រង់យស  នៅក្នុងទីខ្ពស់ ឋានត្រៃត្រឹង្សា ។
ព្រះចូឡាមណី ចេតិយនោះណា  ខ្ញុំសូមវន្ទា ក្រាបថ្វាយបង្គំ
ចំពោះព្រះធាតុ នៃព្រះបរម  ទេវតាតូចធំ មូលមកបូជា ។

**ចត្តាឡីស សមាទន្តា  កេសា លោមា នខាបិ ច**
**ទេវា ហរន្តិ ឯកេកំ  ចក្កវាឡបរម្បរា**
**បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ**

ខ្ញុំសូមបង្គំ ប្រណម្យអភិវាទ  នូវព្រះទន្តធាតុ ទាំងសែសិបផង
និងព្រះកេសធាតុ មុនីនាថជាច្បង  ព្រះលោមធាតុផង និងព្រះនខធាតុ ។
ដែលពួកទេវតា នាំគ្នាខ្មីឃ្មាត  នាំយកព្រះធាតុ មួយអង្គៗ
ទៅកាន់ចក្រវាឡ ដទៃពុំលង់  មួយអង្គៗ ក្នុងចក្រវាឡមួយ ។
ខ្ញុំព្រះករុណា វន្ទាលើកស្ទួយ  បង្គំមួយៗ គ្រប់ទាំងចក្រវាឡ
ដែលពួកទេវតា មនុស្សគ្រប់អាល  បូជាគ្រប់កាល ដោយក្តីជ្រះថ្លា ។

**អដ្ឋារស ទេ្វ វស្សសតេ  ធម្មាសោកោ តទា អហុ**
**ចតុរាសីតិសហស្សា  ចេតិយោ ច ការាបិតា**
**បូជិតា នរទេវេហិ  អហំ វន្ទាមិ ធាតុយោ**

នាកាលព្រះពុទ្ធ- សករាជបាន  •ដោយលោកពោលអាន ទុកជាកំណត់

ពីររយដប់ប្រាំ- បីឆ្នាំប្រាកដ នោះមានមហាក្សត្រ ព្រះនាមហៅថា ។
ព្រះធម្មាសោក ព្រះទ័យជ្រះថ្លា ក្នុងពុទ្ធសាសនា បានសាងចេតិយ
ប្រាំបីម៉ឺនបួន- ពាន់ធួនជាថ្មី ថ្វាយព្រះជិនស្រី ក្នុងពុទ្ធសាសនា ។
ជាទីត្រេកអរ ទាំងមនុស្សទេវតា តែងទៅបូជា ចេតិយទ្រង់យស
ព្រោះមានព្រះធាតុ ប្រសើរខ្ពង់ខ្ពស់ ជាទីអនុគ្រោះ ដល់មនុស្សទេវតា ។
ខ្ញុំសូមបង្គំ ព្រះបរមសាស្តា ចំពោះព្រះមហា ព្រះធាតុទាំងឡាយ
នៅក្នុងចេតិយ ដែលស្តេចសាងថ្វាយ ខ្ញុំសូមឱនកាយ ក្រាបថ្វាយវន្ទា
តេជះបារមី នៃព្រះភគវា ទុក្ខរោគភយា កុំបីកើតមាន សូមសុខ-
សព្វកាល ត្រអាលក្សេមក្សាន្ត សម្បត្តិធនធាន ចម្រើនឥតអាក់ ។
ព្រមទាំងកូនចៅ ញាតិផៅរូមរ័ក្ស កុំបីបែកបាក់ និរាសព្រាត់ព្រាយ
ក្នុងវង្សត្រកូល មិត្រមូលសប្បាយ សម្បត្តិទាំងឡាយ កុំបីខ្វះខាត ។
តាំងពីពេលនេះ រៀង១ រាល់ជាតិ កុំឱ្យឃ្លៀងឃ្លាត ពីក្តីប្រាថ្នា
សូមឱ្យខ្ញុំបាន ដល់ឋានទេវតា និងព្រះមហា និព្វាននាយហោង ។

**ចប់**

❖❖❖

# អស្សយុជបូជា

ពិធីអស្សយុជបូជានេះ មានឫក្សបូជាតែ ១ ពេល សំដៅយកត្រង់នក្ខត្តសម័យ ដែលព្រះសម្ពុទ្ធធ្វើយមកប្បាដិហារ្យចុះចាកទេវលោក នាថ្ងៃពេញបុណ្ណមី ខែអស្សុជនោះ កាលបើដល់វេលាគួរហើយ ត្រូវពួកពុទ្ធបរិស័ទប្រជុំគ្នាតាក់តែងគ្រឿងសក្ការបូជាផ្សេងៗ ថ្វាយចំពោះព្រះរតនត្រ័យ ដូចក្នុងថ្ងៃអាសាឡ្ហបូជានោះដែរ ។ ប្រសិនបើឃើញថាវេលានោះ ជួនជាមានរវល់ដោយព្រះសង្ឃមានកិច្ចធ្វើបវារណាអស់ពេលច្រើនជ្រុល នឹងចាត់ចែងធ្វើពិធីបូជានេះមិនបាន នឹងបង្អង់ខានវិញក៏ឥតមានទាស់ទេ ។

វេរសក្ការបូជា

**ឥទានាយំ ភន្តេ អស្សយុជបុណ្ណមី មហាបវារណាកាលោ សម្បត្តោ តថាគតស្ស ទេវោរោហនកាលសន្និភោ ហោតិ ។ អថខោ ភគវា អម្ហាកំ ទេវលោកំ គច្ឆន្តោ សត្តមេ វស្សេ តាវតឹសភវនេ មាតុគុណមារព្ភ អភិធម្មកថំ កថេន្តោ តត្ថ វស្សំ ឧបេសិ ។ សោ តេមាសច្ចយេន វុដ្ឋវស្សោ សសសំឃេ អស្សយុជបុណ្ណមាយំ ទេវោរោហនសមយេ វិវិធំ ឥទ្ធឹ វិកុព្វិត្វា មនុស្សលោកំ អាគមិ ។ តស្មា មយំ សព្វេ ឥធ សមាគតា តស្ស តក្កាលសន្និភំ អនុស្សរន្តោ ឥមេហិ**

**ទីបធូបមាលាទីហិ សក្ការេហិ ច បុជំ ករិម្ហា ធម្មេហិ ច សាធុ ភន្តេ ភគវា ឥមេ អម្ហាកំ ឧក្ខិត្តបណ្ណាការត្ថេ បដិគ្គណ្ហតុ សាសនស្ស វិរោចនត្ថាយ ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ៕**

ប្រែថា

បពិត្រព្រះករុណាទាំងឡាយដ៏ចម្រើន កាលឥឡូវនេះ ជាថ្ងៃបុណ្ណមីខែអស្សុជ ជាមហាបវារណាកាលមកដល់ហើយ ប្រហែលដូចកាល ដែលព្រះតថាគត យាងចុះចាកទេវលោកពិត ។ ព្រោះថាកាលនោះ ព្រះមានព្រះភាគ ជាអម្ចាស់នៃយើងទាំងឡាយ ស្តេចយាងឡើងទៅឋានទេវលោក សម្តែងអភិធម្មកថា ប្រារព្ធមាតុគុណ ឮដ៏ពិភពតាវត្តិង្ស ក្នុងវស្សាជាគម្រប់ប្រាំពីរ ស្តេចចាំវស្សា ក្នុងឋានតាវត្តិង្សនោះ ។ លុះកន្លង ៣ ខែហើយ ព្រះមានព្រះភាគចេញវស្សារួចហើយ ទ្រង់ធ្វើរិទ្ធិផ្សេងៗ ក្នុងទេវោរោហនសម័យ ថ្ងៃពេញបុណ្ណមី ខែអស្សុជឆ្នាំថោះ ហើយស្តេចចុះមកកាន់មនុស្សលោក ។ ព្រោះហេតុនោះ (កាលឥឡូវនេះ) ខ្ញុំព្រះករុណាទាំងឡាយ មកជួបជុំក្នុងទីសន្និបាតនេះ (ដោយសេចក្តី) រលឹកនូវកាលនោះ របស់ព្រះមានព្រះភាគ បានធ្វើបូជាដោយសក្ការៈទាំងឡាយ មានប្រទីប ធូប ទៀន កម្រងផ្កាជាដើមផង បូជាដោយធម៌ផង បពិត្រព្រះមានព្រះភាគដ៏ចម្រើន សូមព្រះអង្គទទួលនូវគ្រឿង

បណ្ណាការទាំងនេះ ដែលជាទុគ្គតបណ្ណាការ របស់ខ្ញុំព្រះករុណាទាំងឡាយ ដើម្បីការរុងរឿងនៃសាសនាផង ដើម្បីប្រយោជន៍ និងសេចក្តីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

ចប់វេសក្ការៈត្រឹមនេះ

◆◆◆◆◆◆

# រតនប្បណាម

ពុទ្ធោ សុសុទ្ធោ ករុណាមហណ្ណវោ
យោច្ចន្តសុទ្ធព្វរញ្ញាណលោចនោ
លោកស្ស បាបូបកិលេសឃាតកោ
វន្ទាមិ ពុទ្ធំ អហមាទរេន តំ

ធម្មោ បទីបោ វិយ តស្ស សត្ថុនោ
យោ មគ្គបាកាមតភេទភិន្នកោ
លោកុត្តរោ យោ ច តទត្ថទីបនោ
វន្ទាមិ ធម្មំ អហមាទរេន តំ

សង្ឃោ សុខេត្តាភ្យតិខេត្តសញ្ញិតោ
យោ ទិដ្ឋសន្តោ សុគតានុពោធកោ
លោលប្បហីនោ អរិយោ សុមេធសោ
វន្ទាមិ សង្ឃំ អហមាទរេន តំ

ឥច្ចេវមេកន្តភិបូជនេយ្យកំ
វត្ថុត្តយំ វន្ទយតាភិសង្ខតំ
បុញ្ញំ មយា យំ មម សព្វុបទ្ទវា
មា ហោន្តុ វេ តស្ស បភាវសិទ្ធិយា ។

## ប្រែ ឃ្លោងពាក្យ ៧

ព្រះសម្ពុទ្ធម្ចាស់អង្គឯណា ទ្រង់គុណថ្លៃថ្លាល្អម៉ត់ហ្មង
គឺវិសុទ្ធិគុណស្អាតកន្លង ករុណាគុណផងជ្រៅទូលាយ ។
ដូចកល់អន្លង់ធារធំឯក ល្វេងល្វើយអនេកផុតអធិប្បាយ
ទាំងបញ្ញាគុណរុងរឿងឆ្ងាយ ប្រសើរសុសសាយសព្វលើសលប់ ។
ទ្រង់សម្លាប់ចោលគ្រឿងសៅហ្មង បាបកម្មចាំចងសត្វក្នុងភព
ដោយការព្យាយាមមិនឈរឈប់ រាល់ថ្ងៃរាល់យប់សព្វវេលា ។
យើងខ្ញុំបង្គំព្រះពុទ្ធនោះ ល្បីកេរ្តិ៍ឈ្មោះផុតភពភា
ដោយការគោរពដ៏ថ្លៃថ្លា ចិត្តកាយវាចាទាំងបីពិត ។
ព្រះធម៌នៃអង្គព្រះសាស្តា រុងរឿងភ្លឺថ្លាល្អវិចិត្រ
ដូចកល់ប្រទីបខ្មាត់ងងឹត ទ្រោលបំភ្លឺជិតឆ្ងាយក្តីណា ។
ជាធម៌ផ្នែកផ្សេងដោយប្រភេទ មគ្គផលទាំងប៉ែតប្រាំបីឃ្លា
ជាលោកុត្តរឆ្លងលោកា បំភ្លឺប្រាជ្ញាណែប្រយោជន៍ ។
ធម៌ណាដែលខ្ញុំថ្លែងអធិប្បាយ បន្ទែរប្រែស្រាយជ្រៅលន្លោច
ខ្ញុំសូមបង្គំផ្ចង់ចិត្តស្រោច មិនរួញរាញោចចាកធម៌នោះ ។
ព្រះសង្ឃអង្គណាជាស្រែបុណ្យ ល្អល្អះលើសលន់ច្រើនជាន់ស្មោះ
សញ្ញាថាក្រៃឥតចន្លោះ ប្រសើរចំពោះរបស់ជន ។
មានការយល់ត្រូវសន្តានស្ងប់ ជ្រាបធម៌ផងសព្វមិនមោហន្ធ

តាមផ្លូវព្រះសុគតម្ចាស់ទិញតន់ លះការទាបទន់ក្តីឡេះឡោះ ។
ជាអរិយសង្ឃទ្រង់ប្រាជ្ញា គឺស្វាងជ្រះថ្លាឆ្លុះសាយសុស
ទម្លាយកិលេសឥតមានមោះ មន្ទិលពព្រុះក្នុងសន្ដាន ។
ខ្ញុំសូមវន្ទាព្រះសង្ឃនោះ ទ្វារបីចំពោះក្រាបប្រួញប្រាណ
គោរពកោតក្រែងសង្ឃប៉ុន្មាន ដែលបាននិព្វានផុតទុក្ខភ័យ ។
បុណ្យដែលយើងខ្ញុំបានតាក់តែង វន្ទាចាំថែងវត្ថុត្រ័យ
ដែលគួរបូជារាល់សម័យ ជាឯកឥតន័យណាដូចនេះ ។
អន្តរាយទាំងពួងរបស់ខ្ញុំ សូមឱ្យជៅរទុំជ្រុះរបេះ
កុំមានដល់ខ្ញុំអ្នកសំណេះ- សំណាលពោលគុណទាំងបីឡើយ ។
សូមសម្រេចដោយកម្លាំង ដែលយើងខ្ញុំតាំងយ៉ាងនេះហើយ
ចំពោះត្រ័យរ័ត្នម្ចាស់ត្រាណត្រើយ សូមបានសះស្បើយគ្រានេះឯង ។

(បុរាណភាសិត)

## បទគាថានិយាយពីស្តេចទៅកាន់ទេវលោក

តេន ខោបិ សមយេន ពុទ្ធោ យោ លោកនាយកោ
បាដិហារំ ករិត្វាន តាវត្តិំសមុបាគមិ ១
អភិធម្មកថំ កថេត្វា តត្ថ វស្សំ វសី តទា
បវារេត្វាន សោ មុនី ឥមញ្ច បតិរាគមិ ២
អស្សយុជបុណ្ណមេហិ វស្សានោត្តម្ហិ សម្ភូតេ
សង្កស្ស ទ្វារេ ឱតរន្តោ ភូមិយំ សុបតិដ្ឋហិ ៣
សព្វេ ទេវមនុស្សា ច តម្ហូរក្ខា អត្តមនា
សុមនា ច តុដ្ឋចិត្តា សាធុការំ បវត្តីសុ ៣
តស្មា តំ តំ បិ សព្វេសំ នុស្សរន្តា សមាគតា
សក្ការេ អភិសង្ខត្វា តម្ហូជេសុំ យថារហំ ៣

ប្រែ ឃ្លោង ៨ ពាក្យ

សម័យនោះសោតអង្គព្រះសម្ពុទ្ធ ទ្រង់ដូចជាមកុដលើសលោកអង្គណា
លុះទ្រង់ធ្វើឫទ្ធ គឺបាដិហារ្យ ហើយគមនាការកាន់ស្ថានត្រៃត្រឹង្ស ។
សម្តែងធម៌គឺ អភិធម្មជិតឈើង លុះខំរំពឹងទើបប្រស្ថា
កាលនោះព្រះអង្គគង់ចាំវស្សា នាត្រៃត្រឹង្សាសួគ៌ទេវលោក ។
ចេញវស្សាហើយព្រះមុនីចមលោក ស្តេចមានអធ្យោកមកកាន់មនុស្សនេះ
ថ្ងៃដប់ប្រាំកើតអស្សុជផ្កាយសេះ ក្នុងខែបុណ្ណោះជាវដូវភ្លៀង ។

ស្តេចយាងចុះត្រង់ទ្វារក្រុងឥតល្បេង សង្កស្សទាត់ទៀងពីបុរាណនាយ
ប្រតិស្ឋានឈរតម្រង់ព្រះកាយ    លើផែនទូលាយនៃភូមិភាគ ។
លើកករបញ្ចូងលើសិរលំឧត    បង្គំសម្ពុទ្ធថ្វាយវរវន្ទា
ព្រោះហេតុនោះយើងខ្ញុំរាល់រូបា    រលឹកកាលគ្រានោះឯងពុំដាច់ ។
របស់មនុស្សនិងទេព្តាញាតិសាច់    ទើបលះបួរផ្តាច់ហើយមកជុំគ្នា
ចាត់ចែងរៀបចំគ្រឿងសក្ការា    បូជាសាស្តាគួរតាមកម្លាំង ។

(សកភាសិត)

បទគាថា និយាយពីធ្វើយកេបា្បដិហារ្យ រួចហើយ

ជននិយា បមុខានំ    ទេវានំ ហិតការណា
វិតិក្កមំ ករិត្វាន    តាវត្តិង្សមុបាគមំ ។
សមាគតានំ ទេវានំ    មជ្ឈេ បណ្ឌុសិលាតលេ
បារិច្ឆត្តកមូលស្មឹ    និសីទិ បរិសាសតោ ។
សព្វេ ទេវេ អតិគយ្ហ    សម្ពុទ្ធោ ហិ វិរោចតិ
ជនេត្តិយា សហាពលំ    គម្ភីរតរវិជ្ជតំ ។
ឧច្ចោចំ គុណវន្តានំ    អញ្ញេសំ គុណឧច្ចយោ
បស្សមានោ សមាសិន្នោ    វាមទក្ខិណបុព្វកេ
មាតរំ គុណពាហុល្យំ    មានមានោ ហិ នាយកោ ។

ប្រែ ឃ្លោងពាក្យ ៨

រ៍ព្រះលោកជេដ្ឋប្រសើរលើសអស់   ជាងក្រុមបុរសស្តេចពុទ្ធដំណើរ
ទៅកាន់តាវត្តិង្សស្ថានសួគ៌ប្រសើរ   មុនឡើយទ្រង់ដើរជាន់ឈានកន្លង ។
លើចុងដើមស្វាយនិងភ្នំរ៉ៃរផង   ហេតុមានបំណងប្រយោជន៍ទេព្តា
ទាំងអម្បាលមាណមានព្រះម៉ាយា   ពុទ្ធមាតានោះជាប្រធាន ។
ស្តេចដល់ហើយគង់ប្រថាប់នាស្ថាន   ក្រោមដើមថ្កើងថ្កាននៃបារិច្ឆត្តក៏
លើផ្ទៃសិលាថ្មលឿងសាច់មដ្ឋ   កណ្តាលបរិស័ទទេព្តាជួបជុំ ។
ព្រះសម្ពុទ្ធម្ចាស់រុងរឿងត្រសុំ   ដោយរស្មីឃុំគ្របលើទេព្តា
ទ្រង់រំពឹងមើលដោយព្រះប្រាជ្ញា   យល់ច្បាស់គុណាក្រាស់ឥតជិនះ ។
ទាំងជម្រៅជ្រៅទាំងធំខ្ពស់ឈ្មោះ   ព្រះគុណនៃព្រះគុណជននិយា
ខ្ពង់ខ្ពស់ដោយគុណជាងជននានា   ដែលជាមាតាអ្នកមានគុណដែរ ។
ព្រះនាយកគង់ស៊ប់ហើយឆ្មៀងបែរ   ព្រះហឫទ័យគ្មាន់គ្នេររាប់ពួកទេព្តា
ដែលនៅគង់គាល់ព្រះអង្គត្រៀបត្រា   ខាងឆ្វេងស្តាំនាខាងចំភ័ក្ត្រ
និងព្រះមាតាមានគុណជៀងជាក់   យកភ្នំមាសប្រាក់មកប្រៀបពុំបាន ។

(បុរាណភាសិត)

គាថា និយាយពីអានិសង្សស្តាប់ធម៌

**សតំ ហត្ថី សតំ អស្សា   សតំ អស្សតរី រថា**
**សតំ កញ្ញា សហស្សានិ   អាមុត្តមណិកុណ្ឌលា**
**ឯកបទវិហារស្ស   កលំ នគ្ឃន្តិ សោឡសិន្តិ ៕**

## ប្រែ ឃ្លោង ៧ ពាក្យ

ដីរាប់រយសេះរាប់រយ និយាយមេសេះអស្សតរា
ពួករថទឹមសេះរយស្មើគ្នា ពាន់នាងកញ្ញាស្រស់ប៉ប្រិម ។
សឹងពាក់កណ្ដុលជាតិកែវមណី ថ្លាថ្លៃឥតអ្វីនឹងប្រៀបផ្ទឹម
លុះយកមកផ្គួឱ្យត្រូវត្រឹម តម្រឹមនឹងផលជំហានវិញ ។
មិនស្មើសូម្បីមួយចំណិត ដែលអ្នកប្រាជ្ញចិតហើយចែកចេញ
ចែកហើយចែកទៀតរាប់គិតកាញ់ ចម្រាញ់ដល់ដប់ប្រាំមួយដង ។
គង់ថ្លៃអស់នោះនៅតិចពិត មិនស្មើចំណិតតូចឡើយហោង
ផលជំហានតូច-ធំកន្លង ព្រោះមានបំណងស្ដាប់ទេសនា ។

(បុរាណភាសិត)

### បទគាថា និយាយពីបញ្ញាព្រះគន្ធរចនាចារ្យ

**កស្មា គច្ឆតិ ចេ ពុទ្ធោ តាវត្តឹសេ សុរាលយេ**
**សត្ថស្ស បទសោតិ កឹ នុ ខោ តស្ស បាសំសា ។**
**នខោ តស្ស ច បាសំសា ន ច សត្ថស្ស បដ្ឋនា**
**យស្មា តស្មា ហិ សព្វេសំ ឯសា ពុទ្ធាន ធម្មតា ។**
**កត្វាន បាដិហេរញ្ច បទស្សេតិ បទត្តយំ**
**បទត្តយំ បទស្សេត្វា តាវត្តឹសមុបាគមិ ។**
**មាតរំ បមុខំ កត្វា អភិធម្មំ អទេសយិ**

អតិចម្ភកថា តស្មា    ពុទ្ធានញ្ញ ទិសោចកា ៕
កថា អយំ សុតា តុម្ហេ    ឯវំ ចិន្តេថ សាធវោ
ឈានញ្ញា ហិ មយំ បេត្វេ    មាតាបិតូសុ មារិសា ៕
អជ្ជ តេសំ ផលំ សព្វំ    ហន្ទស្សាម ហិ តេ ពលន្តិ ៕

ប្រែ ឃ្លោង ៧ ពាក្យ

ប្រសិនបើព្រះពុទ្ធប្រសើរ    ស្ដេចពុទ្ធដំណើរកាន់ទេវតា
ស្ថានតាវត្តិង្សសួគ៌លោកា    ដោយទ្រង់យល់ថាប្រទេសសត្វ ។
សេចក្ដីសរសើរព្រះសាស្ដា    នឹងមានម្ដេចម្ដាឬបាត់ស្ងាត់
សរសើរអស់នោះនឹងប្រែខ្ចាត់    មិនមានប្រាកដដល់អង្គឬ ។
ថ្នោះអង្គព្រះពុទ្ធទាំងអម្បាលមាណ    មិនទ្រង់ប្រោសប្រាណនឹងបំភ្លឺ
ឱ្យអស់ពួកសត្វមានពន្លឺ    ចុះតើប្រាថ្នាដូចម្ដេចបាន ។
ព្រោះហេតុនោះឯងការយ៉ាងនេះ    ពេញជាតម្រិះព្រះបុរាណ
ធ្វើបាដិហារ្យទៅកាន់ស្ថាន    តាវត្តិង្សពិមានគ្រប់ៗ អង្គ ។
នេះជាទំនៀមតាមធម្មតា    ព្រះពុទ្ធអង្គណាគង់ត្រែកត្រង់
ធ្វើបាដិហារ្យឈានតម្រង់    មិនដែលលះបង់ដល់ម្ដងឡើយ ។
ជំហានព្រះបាទតម្រប់បី(១)    ស្ដេចផ្ទោះដល់ទីត្រៃត្រិង្សហើយ

១-ជំហានទី ១ ព្រះបាទស្ដាំជាន់ចុងស្វាយឈ្មោះគណ្ឌៈ ជំហានតម្រប់ពីរព្រះបាទឆ្វេងជាន់កំពូលភ្នំយុគន្ធរ ជំហានតម្រប់បី ជាន់កំពូលភ្នំសិនេរុ រួបរួមទៅចម្ងាយ ៦៨ សែនយោជន៍ ។

ថ្វៃព្រះមាតាចមត្រាណត្រើយ ចំពោះភក្ត្រហើយទ្រង់អើពើ ។
ផ្លែងអភិធម្មដ៏ជ្រាលជ្រៅ ជម្រៅឥតមានធមិណាស្មើ
ជាធម៌ខ្ពស់ផុតឥតអ្វីបើ នឹងប្រៀបផ្ទឹមស្មើឱ្យសមងាយ ។
ហេតុនោះកថាគឺអភិធម្ម ជាធមិសុខុមធំទូលាយ
ទាំងល្អិតម៉ដ្ឋចត់មិនលំលាយ ព្រះពុទ្ធទាំងឡាយតែងជម្រះ ។
កថានេះខ្ញុំបានស្តាប់ជាក់ អំពីសំណាក់ប្រាជ្ញជ្រៅជ្រះ
នែអ្នកទាំងឡាយកុំបីលះ ចូរខំស្វែងស្វះកុំធ្វេស ។
នែអ្នកទាំងឡាយមានភាពស្មើ ពួកយើងគួរធ្វើកុំប្រហែស
ត្រូវស្គាល់ជម្រៅគុណវិសេស វិសាលក្នុងម្តាយនិងឪពុក ។
ព្រោះយើងទាំងពួងឃើញកម្លាំង បុណ្យផលកំបាំងខាំងលាក់មុខ
មាតាបិតាលោកទ្រាំទុក្ខ សន្តានរំអុកក្នុងថ្ងៃនេះ ។

(បុរាណភាសិត)

បទគាថា និយាយពីស្តេចចុះចាកទេវលោក

**តនាហិ នាថោ បវរោ ច ពុទ្ធោ**
**វស្សំ បវារេសិ អរោច សគ្គំ**
**គច្ឆាមិ មានុស្សបថំ មយទាតិ**
**បុរិន្ទនោ តំ វចនម្បិ សុត្វា**
**តថាគតស្សេវ សុវណ្ណសោបា~**

ណតំ រូបិសោបាណមណិសុបាណ-
ញ្ញាតិ[១] ហិ តិណ្ណំ ទ្វារសោបាណានំ
សុមាបយិត្វា ខណមេ ភវេសោ,
សិនេរុមុទ្ធេ អចលេវ សោបា-
ណានំ បិ សីសានិ បតិដ្ឋហេសុំ
សង្ខស្ស ទ្វារេ សុបតិដ្ឋហេសុំ
តថា ច បាទានិ វរានិ តេសំ
ឥមេសុ ពុទ្ធស្ស ទក្ខិណបស្សេ
ទេវានមាហោសិ ហរីសុបាណំ[២]
តស្សេវ វាមេ រជតំ សុបាណំ
អហោសិ ព្រហ្មស្ស សមាគតស្ស
មណីមយំ មជ្ឈិមមុនិ[៣] សុបាណំ
សព្វញ្ញុនោ បាតុភវេ អមុស្មឹ
សត្ថា សិនេរុម្ហិ ឋិតោវ កត្វា
ឱលោកិតោ សព្វទិសំ វិបូទ្ធិ[៤]
អធោវ យាមាទិចិតោ បិ ឯកំ

---

១-រូបិសោបាណមណិសោបាណញ្ញាតិ រូបិយសោបាណំ មណិសោបាណញ្ច ឥតិអត្ថោ ។

២-ហរីសុបាណន្តិសុវណ្ណសោបាណំ ឥតិ អត្ថោ ។ ៣-ម ។ ៤-វីបូទ្ធិន្តិ វិវិធំ ឥទ្ធី ឥតិ អត្ថោ ។

ឈាណំ អហោសិ អថ សព្វសោត
ឧទ្ធញ្ច សព្វំ បន ឯកឈាណំ
ភវគ្គព្រហ្មា វិបុលញ្ច យាវ
តទា មនុស្សាបិ អធោ បថព្យា
បស្សិំសុ ទេវេ នុកមេន សព្វេ
ទេវា មនុស្សេសុ អធសីសុ ឧទ្ធំ
តថាគតស្សេវ មហានុភាវេន(១)

ប្រែ បទកាកគតិ

កាលនោះសម្ពុទ្ធ ប្រសើរបំផុត ទីពឹងសត្វា ទ្រង់ស្តេចកាន់ស្ថាន ត្រៃត្រឹង្សសួគ៌ា នៅចាំវស្សា ក្នុងសួគ៌ទេវលោក ។ ចេញវស្សាហើយ ពុំផ្សូរផ្សងឡើយ ទ្រង់ពោលហៅរក សម្តេចឥន្ទ្រា ចមពលទេវលោក ដោយពុទ្ធធ្យោក ដូច្នេះឯងថា ។ នែមឃវាន តថាគតមាន ដំណើរយាត្រា ទៅកាន់ផ្លូវមនុស្ស ថ្ងៃបវារណា សល់នៅទិវា ប្រាំពីរទៀតទេ ។ ប៊ុរិន្ទស្តេច ស្តាប់ ព្រះតម្រាស់គាប់ នោះត្រេកឥតឯ ហើយទើបនិម្មិត ជណ្តើរវរ ល្អទាំងកាំមេ ថ្វាយតថាគត ។ ជណ្តើរទាំងបី មួយមាសសោភី មួយប្រាក់ សាច់ស្អិត មួយទៀតកែវមណី មានរស្មីសិទ្ធ រូសរាន់ទាន់ចិត្ត ឆាប់ដូងបំណង ។ ឯក្បាលជណ្តើរ ទាំងបីប្រសើរ ប្រតិស្ថានរង លើកំពូលភ្នំ

១-នាតិ បាទសេសំ ។

ខ្ពស់ធំចម្បង[១] ឬជ្រៅកន្លង រឹងមិនញាប់ញ័រ ។ រ៉ជើងជណ្ដើរ សម្រាប់ដំណើរ ទាំងបីបវរ ប្រតិស្ឋាននៅ ត្រង់ទ្វារនគរ សង្កស្សនាមករ ទាំងបីដូចគ្នា ។ ព្រះឥន្ទនិម្មិត ជណ្ដើរបីពិត ថ្វាយព្រះភគវា ជណ្ដើរហេរិ[២] ទពួកទេវតា ខាងស្ដាំពុទ្ធា អម្ចាស់នៃយើង ។ រ៉ជណ្ដើរប្រាក់ រំលេចចម្លាក់ សឹងទិព្វថ្កុំថ្កើង មានដល់ពួកព្រហ្ម ហែហមតម្កើង ខាងឆ្វេងម្ចាស់យើង គួរតាមវិធី ។ ឯជណ្ដើរកែវ រស្មីពណ៌ខៀវ ចំកណ្ដាលទី ប្រាកដដល់អង្គ សម្ពុទ្ធមុនី ជ្រាបសព្វវាទី នាគ្រាកាលនោះ ។ អង្គព្រះសាស្ដា ស្ដេចស្ថិតនៅនា សិនេរុខ្ពស់ ព្រះនេត្រឆ្មៀងមើល សព្វទិសទាំងអស់ ទ្រង់សម្ដែងយស ធ្វើឫទ្ធិផ្សេងៗ ។ ខាងក្រោមតាំងពី នរកអវិចិ វាលស្រឡះធេង ពន្លឺតែមួយ ដូចទ្រូយស្ងួរសែង រស្មីភ្លឺទែង ឆ្លុះសព្វទិសា ។ ចំណែកខាងលើ វាលធំឥតបើ នឹងរាប់ត្រួតត្រា ភ្លឺជាប់ជាមួយ ជំនួយតគ្នា តាំងពីព្រហ្មា ជាន់ខ្ពស់បង្អស់ ។ ពួកមនុស្សខាងក្រោម មើលឃើញរូបឆោម ពួកទេព-សប្បុរស ទូទៅរហូត លំដាប់វាលនោះ ពុំមានចន្លោះ កាលគ្រានោះណា ។ ពួកទេពខាងលើ ឃើញមនុស្សស្មោះស្មើ ច្បាស់លាលដូចគ្នា ដោយអានុភាព គុណអនន្ដា អង្គព្រះតថា- គតម្ចាស់យើងហោង ។ (សកភាសិត)

បទគាថានិយាយពីស្ដេចធ្វើបាដិហារ្យចុះចាកទេវលោក

**យមកបាដិហារិយំ ញាណេន ឋត្វា តថាគតោ**

---

១-ភ្នំសិនេរុ ឬភ្នំព្រះសុមេរ ។ ២-ជណ្ដើរហេរិ គឺជណ្ដើរមាស អភិធានប្បទីបិកា ។

អកាសិ ពុទ្ធវិសយំ   ឥទ្ធឹ អនេកប្បការំ ៗ
សត្ត កាយា សម្ហុតា   នីលា បីតា ច លោហិតា
ឱទាតា បិ ច មញ្ជេដ្ឋា   សុបភស្សរនាមកា ៗ
ធាវន្តិ វិធាវន្តិ   ចប្ពុរន្តិ បរាបរំ
ជោតយន្តិ ទិសា សព្វា   ឆព្វណ្ណវិធរំសិយោ ៗ
សត្ថា តស្មឹ ខណេ តិដ្ឋំ   និសីទំ វិចរំ សយំ
ឧភោ ចន្ទញ្ច សុរិយញ្ច   ហត្ថេនាបិ បរាមសិ ៗ
បមោចេសិ ជលំ កាយា   តតោ អគ្គិ បមោចយិ
ឧទ្ធំ កាយា អធោ កាយា   សត្ថា តំ បរិវត្តយិ ៗ
យតោ កាយា ជលំ មុញ្ចិ   តតោ អគ្គិ បមុញ្ចយិ
យតោ អគ្គិ បមោចេសិ   តតោ ជលំ បមោចយិ ៗ
លហុំ ជលញ្ច អគ្គិ ច   ជាយន្តិ យមកា វិយ
យមកំ បាដិហីរិយន្តិ   តេន វុច្ចន្តិ បណ្ឌិតា ៗ

ប្រែ បទពំនោល

តថាគតស្ថិតនៅក្នុងញាណ ជាគុណចំណាន នៃបាដិហារ្យថ្លៃថ្នូរ
ទ្រង់ធ្វើឫទ្ធិផ្លាស់ប្តូរ ទឹកភ្លើងសម្បូណ៌ សឹងច្រើនប្រការអនេក ។
ឫទ្ធិសោតអស្ចារ្យពន់ពេក ហៅពេញចម្លែក ជាពុទ្ធវិស័យប្រាកដ ។
រស្មីពណ៌ខៀវលឿងអត់ ក្រហមស-មដ្ឋ ហង្សបាទពព្រុះភ្លឺផ្លេក ។ ស្ទុះ

ទៅស្ទុះមកដោយខ្សែក ផ្សាយឆ្វាយអតិរេក ទៅ១មក១មិនឈប់ ។ ចេញចាកប្រជុំកាយសព្វ នៃអង្គចមភព ជាព្រះបរមគ្រូ ។ រស្មីបីគួបរិបូណ៌ ពណ៌ប្រាំមួយជួរ រុងរឿងប្រផូរសព្វ ទិស ។ ឯអង្គសាស្តាឆោមស្រស់ សណ្ដូកព្រះហស្ត ចាប់ចន្ទសុរិយៈទាំងទ្វី ។ ដែលឈរអង្គុយចរក្តី ផ្ទំដោយសិរី នៅនាអាកាសវេហាស៍ ។ បញ្ចេញទឹកពីកាយា អគ្គិជាលា ក៏ផ្សាយចាកកាយឯងឯ ។ ព្រះអង្គផ្លាស់ប្តូរបែរបេរ ទឹកភ្លើងទាំងទ្វេ ពីកាយខាងលើនិងក្រោម ទទឹកហូរដូចប្រឡោម ចេញទៅតាមរោម ពីចំណែកកាយខាងណា ។ ក្នុងភ្លើងក៏ឥតបើថា ចេញចាកកាយា ចំណែកខាងនោះដូចគ្នា ។ អគ្គិវិលវេញឆ្វេឆ្វា ចេញចាកសរីរា ត្រង់ទីចន្លោះទទឹក ។ ឯទឹកហូរជោររអិក មិនមានភ្លាំងភ្លឹក ចេញចាកទីនោះប្រជែង ។ ទឹកភ្លើងដូចនឹងចំបែង ប្រណាំងគ្នាឯង មួយគួ១ យ៉ាងលឿន ។ ធ្វើឫទ្ធិទាំងពីរគ្រឿន ១ មិនឱ្យចាញ់ល្បឿន ផយថោកជាងគ្នាមួយ១ ។ ពួកប្រាជ្ញជាតិពន្លកត្រួយ តែងពោល ជ្រោងស្ទួយ ដោយនូវប្រការដូច្នោះឯង ។

(សកភាសិត)

ឧទានរបស់ព្រះសារិបុត្ត

**គច្ឆាយ ពាលុកា ខីយេ ឧទកំ ខីយេ មហណ្ណវេ**

**មហិយា មត្តិក ខីយេ ន ខីយេ មម ពុទ្ធិតំ**

**លោកនាថ បវេទ្វាន យេ ចញ្ញេ អត្ថិ ធាណិនោ**

## បញ្ញាយ សារីបុត្តស្ស    កលំ នគ្ឃន្តិ សោឡសី ៥

ប្រែ បទកាកគតិ

ដីខ្សាច់ក្នុងស្ទឹង មិនជាប់នៅនឹង តែងហូរបាត់បង់ ទឹកអន្លង់ជ្រៅ វែងទៅពុំគង់ ដីក្នុងកំលង់ ភូមិប្រឋពី ។ តែងអស់រលោះ មីនតាំងស្ថានសោះ ដូចដើមពេញទី សឹងរបេះបាត់ ខ្ចាត់ទៅទីថ្មី សភាពនោះក្តី ជាគ្រឿងឧបមា ។ ឯប្រាជ្ញាខ្ញុំ រីកចម្រើនធំ មិនអស់ឡើយណា បើប្រៀបធៀបដោយ អ្នកក្រោយនានា ដែលមានប្រាជ្ញា លើកតែលោកងាថ ។ ប្រាជ្ញាអ្នកនោះ មកផ្ទឹមស្មើស្មោះ ផ្ទុំនឹងរូបមាឱ ប្រាជ្ញាសារីបុត្ត ដែលចិត្តសម្អាត ចិត្តលុះដល់ខ្ចាត ដប់ប្រាំមួយដង ។ គង់នៅតូចជាងប្រហែលរូបរាង សន្ទូចជាម្តង ប្រាជ្ញាសារីបុត្ត ធំផុតកន្លង បទនេះឯងហោង ជាគ្រឿងឧបមេយ្យ ។ (បូរាណភាសិត) ប.

ចប់វិធីអស្សយុជបូជាតែប៉ុណ្ណេះ

# មាឃបូជា

ពិធីមាឃបូជានេះ ជាសម័យដ៏ធំមួយ សឹងមាននក្ខត្តឫក្សគួរធ្វើបូជាសក្ការៈដល់ពីរដង គឺ សំដៅយកត្រង់ថ្ងៃដែលទ្រង់សំដែងឱវាទ-ប្បាតិមោក្ខម្តង, ត្រង់ថ្ងៃដែលទ្រង់ដាក់ជន្មាយុម្តង ទើបអ្នកប្រាជ្ញបុរាណលើកយកថ្ងៃពេញបូណ៌មីខែមាឃ ទុកជាពិធីធ្វើសក្ការៈបូជាដរាបដល់សព្វថ្ងៃនេះ ។

ឯរបៀបរៀបចំតាក់តែងគ្រឿងសក្ការៈផ្សេងៗ មិនប្លែកគ្នាអំពីពិធីដែលមានមកហើយនោះៗ ទេ ផ្សេងគ្នាតែបាលីសម្រាប់វេរគ្រឿងសក្ការៈតែប៉ុណ្ណោះ ។

វេរ សក្ការបូជា

**អជ្ជាយំ ភោន្តោ មាឃបុណ្ណមី សម្បត្តា មាឃនក្ខត្តេន យុត្តោ បុណ្ណចន្ទោ ហោតិ តទា ហិ អរហន្តសម្មាសម្ពុទ្ធោ វេឡុវនេ កលន្ទកនិវាបេ មាឃបុណ្ណមិយំ វឌ្ឍមានកច្ឆា-យាយ ចតុរង្គិកេ សាវកសន្និបាតេ ឱវាទប្បាតិមោក្ខំ ឧទ្ទិសិត្វា វិសុទ្ធុបោសថំ អកាសិ សព្វេសំ ខីណាសវា-នំយេវ អឌ្ឍតេឡសានិ ភិក្ខុសតានិ ឧ អថ ច បន អម្ហាកំ លោកនាយកោ ចាបាលចេតិយេ សតោ សម្បជានោ អសី-**

**ភិយោ វស្សកាលេ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថា-គតោ បរិនិព្វាយិស្សាមីតិ អាយុសង្ខារំ ឱស្សជ្ជិ ឱស្សជ្ជិត្វា ច បន ភូមិចាលោ អហោសិ ។ តេនហិ មយន្ទានិ ឥមំ មាឃបុណ្ណមី នក្ខត្តសមយំ យថាតក្កាលសទិសំ សម្បត្តា តស្ស តំ តំ អនុស្សរមានា ឥធ សមាគតា រតនត្តយស្ស ឥមេហិ ទីបធូបបុប្ផាទិសក្ការេហិ អភិបូជេម សាធុ នោ ភន្តេ ភគវា សសាវកសង្ឃោ សុចិរបរិនិព្វុតោបិ ឥមេ សក្ការេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។**

បពិត្រលោកទាំងឡាយដ៏ចម្រើន ថ្ងៃនេះ ជាថ្ងៃមាឃបុណ្ណមីដល់ព្រមហើយ ប្រកបហើយដោយមាឃនក្ខត្តឫក្ស មានព្រះចន្ទពេញវង់ប្រាកដ, សេចក្តីពិតថា ព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ប្រថាប់នៅ ក្នុងវេឡុវ័នកលន្ទនិវាបស្ថាន សម្តែងនូវឱវាទប្បាតិមោក្ខ ធ្វើវិសុទ្ធិឧបោសថអំពោះភិក្ខុដប់បីរយដោយកន្លះ គឺ (១២៥០) អង្គ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ក្នុងទីប្រជុំសាវ័ក ប្រកបដោយអង្គ ៤ វេលារសៀលថ្ងៃពេញបូណ៌មីខែមាឃ ។

មួយវិញទៀត សម្តេចព្រះលោកនាយក អម្ចាស់នៃយើង ទ្រង់ប្រថាប់នៅ ក្នុងបាវាលចេតិយ ទ្រង់មានសតិសម្បជញ្ញៈ ដាក់ចុះនូវ

ជន្មាយុសង្ខារថា កន្លងទៅបីខែទៀត រាប់តាំងអំពីខែនេះ តថាគតនឹងបរិនិព្វាន គម្រប់ជន្មាយុ ៨០ ឆ្នាំគត់ លុះទ្រង់ដាក់ជន្មាយុសង្ខារហើយ ក៏កើតញាប់ញ័រផែនដី ។ ព្រោះហេតុនោះឥឡូវនេះ យើងខ្ញុំទាំងឡាយ (បើ) ដល់ថ្ងៃមាឃបុណ្ណមី ជានក្ខត្តសម័យ ប្រហែលដូចមាឃនក្ខត្តសម័យកាលនោះ ក៏រឭកដល់នូវកាលទាំងពីរនោះ ។ របស់ព្រះដ៏មានព្រះភាគទើបមកជុំគ្នាក្នុងស្ថាននេះ ធ្វើបូជាចំពោះព្រះរតនត្រ័យ ដោយគ្រឿងសក្ការបូជាទាំងឡាយ មានទៀន ធូប កម្រងផ្កាជាដើមនេះ បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ព្រមទាំងព្រះសង្ឃសាវ័កសូម្បីបរិនិព្វានហើយ ជាយូរអង្វែង សូមទទួលនូវគ្រឿងសក្ការៈទាំងឡាយនេះ ដើម្បីប្រយោជន៍ និងសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

ចប់ វេរសក្ការៈ តែបុំណ្ណោះ

## ថ្វាយគ្រឿងសក្ការៈ មុននឹងសូធ្យនមស្ការ

**ឧកាស ទីបញ្ចិធ ធូបមាលំ**

**គន្ធញ្ច បុប្ផញ្ច ឧឡារបូជំ**

**ភត្វា ច ពុទ្ធំ នរទេវសេដ្ឋំ**

**អមល្លធម្មញ្ច បជោតតូតាំ**

**អនុត្តរំ សព្វគណញ្ច ឧត្តំ**

**ឃាសានចិត្តេន- តិបូជយាមិ**

**មយ្ហំ បិតូនំ ច សញ្ញាតកានំ**

**សុខាយ អត្ថាយ ចិរំ ហិតត្ថំ ខ**

ប្រែ ឃ្លោង ៧ ពាក្យ

សូមទានគោរពពេលនេះឯង ខ្ញុំសូមចាត់ចែងគ្រឿងបូជា
គឺទៀន ធូប កម្រងមាលា ព្រមទាំងគន្ធានឹងភ្ញីផ្កា ។
សំដៅចំពោះព្រះសម្ពុទ្ធ ទ្រង់ប្រសើរផុតមនុស្សទេព្តា
ព្រះធម៌ដែលឥតមន្ទីលណា ជាប្រទីបថ្លាភ្លឺកន្លង ។
ទាំងពួងនៃព្រះអរិយសង្ឃ ដែលទូន្មានអង្គល្អមជ្ឈហ្មង
លោកវិសេសលើសពួកជនផង ដោយនូវទំនងចិត្តជ្រះថ្លា ។
ដើម្បីប្រយោជន៍-សេចក្តីសុខ ចម្រើនគ្រប់មុខដល់ខ្ញុំណា
ព្រមទាំងមាតានូវបិតា និងញាតិកាយូរអង្វែង ។

(ធម្មលិខិតត្ថេរភាសិត)

បទគាថាប្រារព្ធមាឃបូជា

**មាឃនក្ខត្តយុត្តាយ បុណ្ណាយ បុណ្ណមាយ យោ**

**អរហំ សម្មាសម្ពុទ្ធោ ភគវា គោតមវ្ហយោ**

សុទ្ធានន្ទនយោ ញាណោ សត្ថា លោកេ អនុត្តរោ
វិហរន្តោ រាជគ្គហេ មគធានំ គិរិព្វជេ
វិហារេ វេឡុវនេ ច កលន្ទកនិវាបិយេ
សង្ឃស្ស សន្និបាតម្ហិ ឧត្តមេ ចតុរង្គិកេ
អឌ្ឍតេលសេហិ ភិក្ខុ- សតេហិ បរិវារិតោ
តីហិ គាថាហិ សង្ខិប្បំ សព្វំ ពុទ្ធាន សាសនំ
សមោសារេសិ ឱវាទំ បាតិមោក្ខំ អនុត្តរំ
តមេវម្ភុតសម្ពុទ្ធំ សខីណាសវសាវកំ
ចិរកាលមតីតម្បិ បសាទេន អនុស្សរំ
អយម្បិ បរិសា សព្វា បសន្នា ធម្មគាមិនី
សម្បត្តា តាទិសំ ត.សំ សុនក្ខត្តំ សុមង្គលំ
ទីបធូបាទិសក្ការេ អភិសជ្ជ យថាពលំ
តេហិ បូជេ គវេហដ្ឋ- តុដ្ឋា ឥធ សមាគតា
អភិវន្ទតិ បូជេតិ ភគវន្តំ សសាវកំ
កាលេន សម្មុខី ភូតំ អតីតារម្មណត្តនា
ឱសារេន្តំ បាតិមោក្ខំ វិសុទ្ធត្តម្បោសថេ
ឥតោ ជេន សុបុញ្ញេន សោត្ថិ ហោតុ សទាបិ នោ
**សាសនំ សត្ថុ អម្ហាកំ** ចិរំ ទិប្បតុ តាទិនោ ៦

## ប្រែ ឃ្លោង ៧ ពាក្យ

ព្រះមានព្រះភាគអង្គឯណា ទ្រង់ព្រះនាមថាព្រះគោតម
កម្ចាត់កិលេសទាំងតូចធំ មិនឱ្យរួមរុំសន្ដាននៅ ។
ទ្រង់ត្រាស់ដឹងឯងដោយប្រពៃ ឥតគ្រូដទៃប្រៀនប្រដៅ
ទ្រង់មានចរិយាឥតហ្មងសៅ ករុណាឆ្ពោះទៅសត្វគ្រប់គ្នា ។
និងបញ្ញាគុណចាក់ធ្លុះធ្លាយ ជ្រៅឆ្ងាយទូលាយអនន្តា
ព្រះអង្គជាគ្រូក្នុងលោកា ឥតមានគ្រូណាប្រៀបផ្ទឹមបាន ។
ទ្រង់គង់ក្នុងវត្តព្រះវេឡុវ័ន ជាទីកលន្ទនិវាបស្ថាន
ជិតក្រុងរាជគ្រឹះដែនបុរាណ ដែលប្រាកដមានក្នុងមគធា ។
ភិក្ខុអរហន្តដ៏ពណ្ណរាយ ពាន់ពីររយហ្វាយហាសិបណា
ចូលទៅគង់គាល់នៅត្រៀបត្រា កបដោយឋានាដ៏ឧត្តម ។
ហើយទើបព្រះអង្គទ្រង់សន្និបាត សម្ដែងឱវាទប្បាតិមោក្ខសម
ចំពោះភិក្ខុសង្ឃដ៏ឧត្តម ដែលមកជួបជុំនៅពេលនោះ ។
ជាសាសនានៃព្រះពុទ្ធម្ចាស់ គ្រប់អង្គតែងត្រាស់ឥតមានមោះ
យ៉ាងសង្ខេបខ្លីល្អមពីរោះ ដោយគាថានោះតែបីបទ ។
ក្នុងថ្ងៃពេញបូណ៌មីមាឃា កបនក្ខត្តាល្អប្រាកដ
ហើយប្រជុំភិក្ខុកំណត់ ទ្រង់សម្ដែងបទវិនយា ។
ជាច្បាប់សម្រាប់ភិក្ខុខ្ចី ពោលគឺបាលីបាតិមោក្ខា

មានអត្ថបរិសុទ្ធដ៏ថ្លៃថ្លា សូធ្យថ្ងៃឧបោសថាតាមវេណី ។
មួយទៀតកាលអង្គព្រះសុគត សម្រេចឥរិយាបថក្រុងវេសាលី
មានភិក្ខុចោមរោមជាប្រក្រតី ទ្រង់ប្រាប់សេចក្តីឱ្យដឹងដាន ។
ថានៅតែបីខែទៀតទេ ទ្រង់និងបែររេចូលនិព្វាន
បរិស័ទទាំងពួងយើងខ្ញុំមាន ក្តីជ្រះថ្លាបានទាន់ធម៌គ្រប់ ។
យើងខ្ញុំសូមលើកព្រះសម្ពុទ្ធ និងសង្ឃជាបុត្រខីណាស្រព
និព្វានកន្លងយូរថ្ងៃយប់ នឹកមិនមានឈប់ដោយជ្រះថ្លា ។
យើងខ្ញុំបានដល់នក្ខត្តឫក្ស មង្គលអឹកៈធឹកធំណាស់សា
បាននាំគ្នាធ្វើសក្ការា ទៀនធូបជាអាទិ៍តាមប្រឹងប្រែង ។
យើងខ្ញុំមានចិត្តត្រេកអរករាយ ជួបជុំខ្វល់ខ្វាយទីនេះឯង
ដើម្បីសក្ការៈគាក់តែង បូជាកោតក្រែងដោយផ្ចិតផ្ចង់ ។
សូមថ្វាយបង្គំសូមបូជា ឆ្ពោះព្រះភគវាសាវ័កសង្ឃ
តាមកាលឆ្ពោះភក្ត្រនៃព្រះអង្គ និព្វានយូរលង់នោះហើយក្តី ។
កាលដែលសម្តែងព្រះបាដិមោក្ខ ខែមាឃមានជោគបុណ្ណមី
ព្រះចន្ទចាំងចែងរឿងរង្សី ឧបោសថពីសីបរិសុទ្ធា ។
ដោយបុណ្យបូជាដោយសទ្ធា សូស្តីសោភាមានគ្រប់គ្រា
សាសនាសាស្តាយើងរាល់គ្នា ថ្កុំថ្កើងចិរាយូរអង្វែង ។

(បុរាណភាសិត)

### នមស្ការកាលទ្រង់ប្រជុំធ្វើឱវាទបាតិមោក្ខ

**អរហាពុទ្ធ ទេសេន្តំ** **សន្និបាតេ ចតុរង្គិកំ**
**ឱវាទបាតិមោក្ខម្បិ** **មាឃនក្ខត្តទិវសេ**
**បរិសុទ្ធន្តមោវាទំ** **លោកជេដ្ឋេន ភាសិតំ**
**សុណន្តន្តំ ខណពុទ្ធ** **ខីណាសវំ នមាមិហំ ៕**

ប្រែ ឃ្លោង ៧ ពាក្យ

សូមថ្វាយបង្គំព្រះអរហំ គង់ក្នុងចតុរង្គសន្និបាត
ត្រាស់សម្តែងធម៌ដ៏ល្អស្អាត ពោលគឺឱវាទបាតិមោក្ខ ។
ក្នុងថ្ងៃដែលជានក្ខត្តឫក្ស ព្រះចន្ទអឹកៈធឹកផ្ដាយគគោក
ថ្ងៃពេញបុណ្ណមីមាឃមានជោគ ដែលលោកសន្មតឧបោសថា ។
ព្រមទាំងឱវាទដ៏មជ្ឈហ្មង ដែលព្រះជាច្បងក្នុងលោកា
ទ្រង់ត្រាស់ប្រទានធម៌ទេសនា ដល់ព្រះខីណាស្រពនានា ។
ព្រមទាំងព្រះសង្ឃគ្មានចំណោង កិលេសកម្មកង គឺតណ្ហា
ជាខីណាស្រពស្តាប់ទេសនា នៃព្រះសាស្តាគ្រានោះឯង ។

### នមស្ការកាលទ្រង់ដាក់ជន្មាយុសង្ខារ

**អាទិច្ចពន្ធុសព្វញ្ញុំ** **មាឃនក្ខត្តទិវសេ**
**ឱស្សដ្ឋន្តាយុសង្ខារំ** **ឱវទន្តម្បិ ភិក្ខុនំ ៕**
**និយ្យានិកន្តមោវាទំ** **ទិន្នំ អាទិច្ចពន្ធុនា**

## សុវណ្ណានន្ទំ ខណនេត្វា គណុត្តមំ នមាមិហំ ២

ប្រែ ឃ្លោង ៧ ពាក្យ

សូមថ្វាយបង្គំព្រះមារវិជិត ពូជពង្សអាទិត្យឫទ្ធិមហិមា
កាលទ្រង់ដាក់អាយុសង្ខារា បន្ថយជន្មាមិនយូរយារ
ហើយទ្រង់ទេសនាប្រោសប្រដៅ ភិក្ខុដែលនៅគាល់ត្រៀបត្រា
ក្នុងថ្ងៃពេញបូណ៌មាឃមាសា ថ្ងៃនោះក៏ជាឧបោសថពិត
ដែលព្រះជាពូជពង្សវង្សអាទិត្យ ទ្រង់បានពិនិត្យប្រទានណា ។
ព្រមទាំងគណារីយបុគ្គល ឧត្តមសោតសល់ឥតឧបមា
ដែលលោកបានស្តាប់ត្រាប់ទេសនា ក្នុងកាលនោះជាពេលប្រសើរ ។

បទគាថា និយាយអំពីទ្រង់ដាក់ជន្មាយុសង្ខាររួចហើយ ( ក)

## តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជិ មុនិ
## អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវន្តិ ២

ប្រែ បទព្រហ្មគីតិ

ព្រះសម្ពុទ្ធអ្នកប្រាជ្ញ រុងរឿងស្វាចលើសកន្លង ទ្រង់យល់ធម៌មជ្ឈហ្មង គឺព្រះនិព្វានថ្លឹងពុំបាន ។ ទាំងទ្រង់យល់ភពបី ទីអប្រិយនាំរំខាន ទើបលះសង្ខារមាន ដំណើរថ្កានទៅកាន់ភព ។ ព្រះហឫទ័យសឹងស្ងោះសរ ពេញអំណរច្រើនលើសលប់ ក្នុងសន្តានចមភព ទ្រង់ទល់ទប់ដោយការ រៀប ។ ទម្លាយនូវបណ្តាយ ធម៌ស្មុគស្មាញសៅហ្មងសព្វ ដូចក្រោះឱពូកទ័ព

ដែលរុំអប់សន្ដានហើយ ។ ( បុរាណភាសិត)

បទគាថា និយាយពីទ្រង់ដាក់ជន្មាយុសង្ខាររួចហើយ ( ខ)

**ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា**
**អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា**
**យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ**
**ខុទ្ទកញ្ច មហន្តញ្ច យញ្ច(១) បក្កំ យញ្ច អាមកំ**
**សព្វំ ភេទបរិយន្តំ ឯវំ មច្ចានជីវិតំ ២**

ប្រែ ឃ្លោង ៤ ពាក្យ

ពួកជនណា១ ទោះបីក្មេងចាស់ ទោះពាលផ្ដេសផ្ដាស ឬប្រាជ្ញបណ្ឌិត អ្នកមានស្ដុកស្ដម្ភ ឬទ័លក្រក្រិត្ត អ្នកទាំងនោះពិត មានស្លាប់នៅមុខ ។ ប្រៀបដូចចានឆ្នាំង សូនពីដីពុក តូចធំកំប៉ុក ឆ្អិនឆ្អៅម្ដេចម្ដា ភាជន៍ទាំងពួងនោះ តែងបែកប្រេះឆា នៅជាធម្មតា ខាងមុខបំផុត ។ ជីវិតសត្វផង តែងនឹងទ្រោមទ្រុឌ មិនសម្បយុត្ត ដូច្នោះឯងហោង ។

( បុរាណភាសិត)

បទគាថា ទិយាយពីទ្រង់ដាស់តឿន

**បរិបក្កោ វយោ មយ្ហំ បរិត្តំ មម ជីវិតំ**
**បហាយ វោ គមិស្សាមិ កតំ មេ សរណមត្តនោ**
**អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ**

**សុសមាហិតសង្កប្បា   សចិត្តមនុរក្ខថ**
**យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ**
**បហាយ ជាតិសង្សារំ   ទុក្ខស្សន្ត ករិស្សតីតិ**   ២

ប្រែ បទកាកគតិ

យើងជាពុទ្ធោ មានវ័យជរោ ប្រាកដមែនហើយ ជីវិតនៃយើង រស់មិនយូរឡើយ នឹងលះអ្នកហើយ ទៅកាន់និព្វាន ។ រីឯទីពឹង តថាគត ប្រឹង ប្រែងរករុករាន កសាងសន្សំ បម្រុងរូបប្រាណ បីដូចកលស្ពាន សុទ្ធឈើពូកែ ។ នៃអ្នកទាំងឡាយ ចូរខំខ្វល់ខ្វាយ កុំធ្វើធ្វេសធ្វេ ត្រូវមានស្មារតី ចាំកុំបែររេ ត្រូវមានសីលេ ឱ្យខ្ជាប់គត់មត់ ។ ទាំងមាន តម្រិះ ប្រាជ្ញាត្រេកត្រិះ ឱ្យនឹងប្រាកដ ហើយត្រូវរក្សា ចិត្តឱ្យមដួចត់ ខំអត់សង្កត់ រក្សាចិត្តខ្លួន ។ បើអ្នកឯណា មិនធ្វេសឆ្គោះនា ច្បាប់ទម្លាប់ក្បួន គឺធម៌វិន័យ នេះដ៏មាំមួន សឹងនៅថៃថ្នូន គ្រប់ឥរិយាបថ ។ អ្នកនោះសោត ណា លះសង្សារា ដែលនាំបរិវដ្ត ធ្វើព្រះនិព្វាន អច្ចុតបទ ជាដែនរំលត់ ទុក្ខភ័យគ្មានសល់ ។   (បុរាណភាសិត) ម.

បទគាថា និយាយពីទ្រង់សម្ដែងធម៌ ៤ យ៉ាង

**សីលំ សមាធិ បញ្ញា ច   វិមុត្តិ ច អនុត្តរា**
**អនុពុទ្ធា ឥមេ ធម្មា   គោតមេន យសស្សិនា**
**ឥតិ ពុទ្ធោ អភិញ្ញាយ   ធម្មមក្ខាតិ ភិក្ខុនំ**

**ទុក្ខស្សន្តករោ សត្ថា  ចតុរោ បរិនិព្វុតោតិ  ២**

ប្រែ បទព្រហ្មគីតិ

វិធមិ ៤ ប្រការ ព្រះឈ្មោះមារជាអម្ចាស់ គោតមស្ដេចជ្រាបច្បាស់ ទើបទ្រង់ត្រាស់ដូច្នេះថា ។ ទីមួយគឺសីលំ ពីរបញ្ចុំបីសមា- ធិធមិដ៏ថ្លៃថ្លា បួនវិមុត្តិប្រសើរឯក ។ ព្រះពុទ្ធទ្រង់ជ្រាបហើយ ពុំលាក់ឡើយ ទ្រង់ប្រាំ ចែក ធមិនោះដោយចំណែក ដល់ពួកភិក្ខុគ្រប់ប្រការ ។ ព្រះចក្ខុសម្ពុទ្ធ ជាចមដុកសាស្ដាចារ្យ ទ្រង់ឆ្លងវដ្ដសង្សារ រួចផុតទុក្ខឥតមានសល់ ។ ព្រះអង្គស្ដេចនិព្វាន សុខសម្រាន្តគ្មានសល់វល់ តណ្ហាទៅមិនដល់ ពុំមាន ចាស់ឈឺស្លាប់ឡើយ ។ (បុរាណភាសិត)

គុណព្រះនិព្វាន ៨ យ៉ាង

**មទនិម្មទនោ ហោតិ  បិបាសវិនយោ បិ ច**

**អាលយសមុគ្ឃាដោ ច  វដ្ដច្ឆេទោ ច ហោតិ វា**

**តណ្ហក្ខយោ វិរាគោ ច  និរោធោ ចាបិ និព្វានំ**

ប្រែ បទមណ្ឌូកគតិ

១- គុណព្រះនិព្វាន ទ្រង់ត្រាស់ថាមានប្រាំបី មួយតាំងដើមទីកាច់ កិនញាំញីស្រវឹង ។ ២- ទីពីរតទៅ លះស្រេកឃ្លានម៉ោរឹងប៉ឹង គឺកាមគុណ ហ្នឹង ឱ្យអស់សូន្យឈឹងបង់សៀត ។ ៣- ទីបីថ្លាថ្លៃដកចោលអាល័យកាម

ទៀត ដែលនៅប្រជ្រៀត ធ្វើឱ្យចង្អៀតឥតល្ហែ ។ ៤- ទីបួនវិញថ្វាត់ ជាគុណប្រូតកាត់ក្តីស្នេហ៍ ដែលជាប់តខ្សែ ឱ្យដាច់ងាករវេចាកវដ្ត ។ ៥- ទីប្រាំគុណខ្ពស់ អ្នកធ្វើឱ្យអស់ប្រាកដ តណ្ហារបស់សត្វ រលាយរលត់គ្មានខ្ចប់ ។ ៦- ទីប្រាំមួយនៃ ជាគុណនាំក្ស័យកង្វល់ តម្រេកឥតស្តល់ គឺធ្វើឱ្យអស់គ្មានរាគ ។ ៧- ទីប្រាំពីរសោត នាមថានិរោធជាពាក្យ រលត់អស់រាគ ផុតទុក្ខលំបាករលីង ។ ៨- ទីប្រាំបីគ្រប់ ជាគុណគម្រប់តំណែង តួនិព្វានឯង មានគុណនឹងថ្លែងពុំបាន ។ (សកភាសិត)

ពាក្យនមស្ការ

**សព្វញ្ញូសត្ថា** **គវវានវន្ទោ**
**អនាថនាថោ** **គវសត្តតារី**
**វិសុទ្ធិសុទ្ធ** **ត្តសុមគ្គទ្ទេសី**
**មោក្ខប្បទាយី** **គុណធាតុ នោនោ**

ប្រែ បទព្រហ្មគីតិ

សព្វញ្ញូសាស្តា កាត់តណ្ហាការលោកិយ រើសសត្វចាកភពបីដាក់ដល់ត្រើយព្រះនិព្វាន ។ បង្ហាញផ្លូវមគ្គផល កាត់កង្វល់លោកិយបាន ជាគ្រូយើងគ្រប់ប្រាណ ទ្រង់រក្សាអស់យើងខ្ញុំ ។ (លោកអាចារ្យ អ៊ុក-ជា)

**ចតុរង្គសន្និបាតរបស់ព្រះបរមគ្រូយើងមានអង្គ ៤ គឺ**

១- **មាឃនក្ខត្តេន យុត្តោ** ថ្ងៃឧបោសថ ១៥ កើត ខែមាឃ

ប្រកបដោយមាយនក្ខត្តឫក្ស ។

២- **កេនចិ អនាមន្តិតា** ព្រះអរហន្ត ១២៥០ រូប ឥតមាន

គេនិមន្ត ស្រាប់តែមកជុំគ្នាតាមធម្មតា ។

៣- **តេសុ ឯកោ បុថុជ្ជនោ** បណ្តាព្រះអរហន្តទាំងនោះ ឥត

មានបុថុជ្ជន- សេក្ខបុគ្គលនិងអរហន្តសុខ.ស្រុកៈដល់ ១ អង្គឡើយ

សុទ្ធតែជាព្រះខីណាស្រពទាំងអស់ ។

៤- **ឯកោបិ ចេត្ថ សត្ថេន** ឥតមានអង្គណាមួយ កោរ

ព្រះកេសដោយកាំបិតហើយបួសឡើយ សុទ្ធតែជា **ឯហិភិក្ខុ** ទាំងអស់ ។

ចប់វិធីមាឃបូជាតែប៉ុណ្ណេះ

ថ្ងៃ ២ ។ ១១ ឆ្នាំរោងសំរិទ្ធិស័ក ព.ស. ២៥៣២ គ.ស. ៧-១១-១៩៨៨

១១

*****

# ពិធីពុទ្ធាភិសេក

ដែល

## សម្តេចព្រះមហាសុមេធាធិបតី

ជ.ណ. ជោតញ្ញាណោ

## ព្រះសង្ឃរាជ គណៈមហានិកាយ

រៀបរៀង

បោះពុម្ពគ្រាទី ៣

ព.ស. ២៥១៥ គ.ស. ១៩៧២

# ពិធីពុទ្ធាភិសេក

ការស្រោចស្រប់ ឬជជុះរលាស់ ប្រោះព្រំនូវសុគន្ធវារីថ្វាយព្រះពុទ្ធរូបដែលទើបកសាងថ្មី ហៅថា **ពុទ្ធាភិសេក** ។ ពិធីនេះជាប្រពៃណី ដែលពុទ្ធបរិស័ទបានធ្វើអស់កាលយូរអង្វែងហើយ ជាប់មានដរាបមកដល់សម័យយើងសព្វថ្ងៃ ។ បណ្ឌិតអ្នកប្រាជ្ញ ទ្ធសាសនិកទាំងឡាយ មាន **ព្រះនាគសេនមហាថេរ** ជាដើម បានធ្វើតាមលំអានរឿងដែល **ព្រះមហាបុរស_សិទ្ធត្ថ_សក្យមុនី_គោតម** ទ្រង់បានត្រាស់ដឹងនូវ **អនុត្តរសម្មាសម្ពោធិ** បានដល់នូវ នះជា **ព្រះអរហន្តសម្មាសម្ពុទ្ធ** ប្រាកដឡើង នៅពេលខាងចុងបច្ឆិមយាមនៃរាត្រីពេញបូណ៌មីខែពិសាខនោះ, គ្រាន់តែព្រះអង្គបានផ្ចាញ់មារហើយបានត្រាស់ថា **ព្រះសម្ពុទ្ធ** ភ្លាមក៏កើតមានអព្ភូតហេតុជាមហាស្ចារ្យ ទេពតាឥន្ទព្រហ្មទាំងឡាយ និម្មិតខ្លួនតូចៗ ល្អិតៗ មកប្រជ្រៀងគ្នាណែនណាន់តាន់តាប់ បន្លឺវាចាអឺងអាប់ ថ្វាយពរថ្វាយជ័យចំពោះព្រះសម្មាសម្ពុទ្ធថា "**ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ! មារមានបាបចាញ់ព្រះអង្គហើយ**(១) !" ពិតត្រឹមតែបន្លឺឧក្ឃោសនវាចាថ្វាយពរជ័យប៉ុណ្ណោះទេ, ទេពតាឥន្ទព្រហ្មទាំងនោះ ថែមទាំងបាចសាចសុគន្ធបុប្ផាទិព្វប្រោះព្រំសុគន្ធវារីទិព្វ, គន្ធព្វទេពតាទាំងឡាយប្រគំតូរ្យតន្ត្រីទិព្វថ្វាយពរថ្វាយជ័យចំពោះព្រះសព្វញ្ញូសម្ពុទ្ធផងទៀត,

១-ឧក្ឃោសនាការនេះ នឹងមានបាលីគាថាប្រាប់ទៅខាងមុខក្នុងពិធីពុទ្ធាភិសេកសង្ខេប ។ ចូរអានគាថានោះចុះ ។

ដោយអំណរដ៏ក្រៃលែង ។ ព្រះមហាបុរសទ្រង់បានត្រាស់ច្បាស់ជា **ព្រះអរហន្តសម្មាសម្ពុទ្ធ** រួចស្រេចហើយយ៉ាងនេះ ទើបអទិស្សមានកាយ[១] ទាំងឡាយមានទេពតាជាដើម បាននាំគ្នាចូលមកសម្តែងសេចក្តីគោរពចំពោះព្រះអង្គ ។ ព្រោះហេតុនេះឯង បានជាពិធីនេះឈ្មោះថា **ពុទ្ធាភិសេក** គឺ ការបាចសាចប្រោះព្រំសុគន្ធបុប្ផានិងសុគន្ធវារីទិព្វ ថ្វាយស័ព្ទសាធុការពរជ័យ ចំពោះព្រះអង្គដោយសោមនស្សចិត្ត និងសេចក្តីជ្រះថ្លាក្រៃលែងនៃពពួកអទិស្សមានកាយមានទេពតាជាដើម បន្ទាប់ពីវេលាដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធរួចស្រេចហើយ. **ពុំមែនព្រះអង្គបានត្រាស់ជាព្រះសម្ពុទ្ធដោយសារពពួកអទិស្សមានកាយថ្វាយព្រះអង្គទេ** ។ ព្រោះហេតុនេះហើយ បានជាព្រះពុទ្ធទ្រង់មានព្រះ **នេមិត្តិកនាម** ថា **សម្មាសម្ពុទ្ធោ** ដែលមានអត្ថន័យថា "ព្រះអង្គត្រាស់ដឹងដោយប្រពៃនូវញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង ឥតមានទេពតាឥន្ទព្រហ្មឬមនុស្សណាធ្វើឱ្យព្រះអង្គបានត្រាស់ឡើយ" ។

ដោយមានរឿងនេះជាមូលហេតុ, ទើបពុទ្ធបរិស័ទគ្រប់ប្រទេស ធ្វើពិធីពុទ្ធាភិសេក ។ ពិធីនេះ ពុំសុទ្ធតែដូចគ្នាតែបែបមួយទេ គឺពុទ្ធសាសនិកជនខ្លះធ្វើដោយពិធីពិស្តារ ខ្លះធ្វើដោយពិធីមធ្យមយ៉ាងកណ្តាល ខ្លះធ្វើដោយពិធីសង្ខេបខ្លី តាមយោបល់និងតាមការលៃលក កុំឱ្យតែខានពុំបាន

---

១-អទិស្សមានកាយ ប្រែថា "សត្វកិលេសដែលមានរូបរាងកាយ ប៉ុន្តែមនុស្សយើងមើលពុំឃើញ" ។

ធ្វើពិធីនោះសោះប៉ុណ្ណោះ ព្រោះគេជឿជាក់ថា ព្រះពុទ្ធរូបដែលគេបានកសាងថ្មីនោះ ទុកស្មើដូចអង្គព្រះពុទ្ធ ដែលទើបបានត្រាស់ដឹងនូវអនុត្តរ-សម្មាសម្ពោធិថ្មីៗ , គេគ្រាន់តែធ្វើពិធីអភិសេករំលឹកតាមលំអានរឿងនោះ កុំឱ្យតែខានធ្វើសោះ ដើម្បីឱ្យបានផលានិសង្សជាថ្មីថែមឡើងទៀតប៉ុណ្ណោះ, គេពុំមែនយល់ថា អភិសេកព្រះពុទ្ធរូបអង្គថ្មីឱ្យបានត្រាស់ទេ ។

**ពិធីពុទ្ធាភិសេកពិស្ដារ**ៗនៅប្រទេសកម្ពុជា សឹងមានពណ៌នាក្នុងក្បួនបុរាណស្រាប់ហើយ ខ្ញុំមិនបាច់ថ្លែងទេ, ការគួរធ្វើដោយសព្វគ្រប់តាមក្បួនបុរាណ និងការមិនគួរធ្វើត្រង់ពិធីណាខ្លះនោះ គួរពុទ្ធបរិស័ទពិចារណារិះរេដោយហ្មត់ចត់ឱ្យឃើញតាមការណ៍ពិត និងការណ៍ពុំពិតចុះ ។

ក្នុងពិធីពុទ្ធាភិសេកពិស្ដារនោះ, មានពុទ្ធសាសនិកជនបរទេសខ្លះ គេធ្វើឱ្យត្រូវត្រង់ថ្ងៃ ១៤ កើតនិងថ្ងៃ ១៥ កើតខែពិសាខ តាមតែក្នុងឆ្នាំណាក៏ដោយ ។ នៅថ្ងៃ ១៤ កើតគេរៀបគ្រឿងសក្ការបូជាថ្វាយព្រះពុទ្ធរូបអង្គថ្មី តាំងពីពេលព្រលប់រហូតដល់ភ្លឺ គេធ្វើពិធីចម្អិនមធុបាយាស ដែលហៅថា **និរុទកមធុបាយាស** គឺមធុបាយាសគោកគួរពូតជាពំនូតបាន ។ គេថ្វាយព្រះពុទ្ធរូបអង្គថ្មី នៅពេលព្រឹកព្រលឹមថ្ងៃ ១៥ កើត ខែពិសាខ ឱ្យត្រូវតាមលំអានរឿងនៃនាងសុជាតា ដែលថ្វាយមធុបាយាសចំពោះ **ព្រះសទ្ធត្ថៈសក្យមុនីៈគោតម** ។ នៅថ្ងៃ ១៥ កើតខែពិសាខនោះ, តាំងពីពេលព្រលប់រហូតដល់ភ្លឺ ជាពិធីពុទ្ធាភិសេក ។ គេបញ្ចប់ពិធីនេះទៅ

ពេលព្រឹកនៃថ្ងៃ ១ រោច ។

**ពិធីពុទ្ធាភិសេកមធ្យម**~ គឺពិធីយ៉ាងកណ្ដាល មិនវែងមិនខ្លីពេក ។ តាមប្រពៃណីឬទម្លាប់ក្នុងប្រទេសកម្ពុជាយើង: ទោះនៅថ្ងៃ-ខែ-ឆ្នាំណោក៏ដោយ, ពុទ្ធបរិស័ទធ្វើពិធីពុទ្ធាភិសេកមានរបៀបជារយៈ ៥ សង្កាត់គឺ **សង្កាត់ទី ១**- រៀបគ្រឿងសក្ការបូជាមានផ្កាស្រស់ៗ និងទៀនធូបជាដើមថ្វាយព្រះពុទ្ធរូបអង្គថ្មី ។ **សង្កាត់ទី ២**- និមន្តព្រះភិក្ខុសង្ឃចម្រើនព្រះបរិត្ត ។ **សង្កាត់ទី ៣**- និមន្តព្រះធម្មកថិកមួយអង្គសម្ដែងរឿងបឋមត្រាស់ ។ **សង្កាត់ទី ៤**- និមន្តព្រះភិក្ខុមួយអង្គឬពីរព្រះអង្គសូធ្យបាលីពុទ្ធាភិសេក ។ **សង្កាត់ទី ៥**- សូធ្យបទ **ធម្មប្បដិយោគ** ដែលធ្លាប់ហៅថា **ធមិយោគ** ។ **សង្កាត់ទី ៦**- សូធ្យបទ **ផ្ចាញ់មារ**(១) ។ **សង្កាត់ទី ៧**- និមន្តព្រះសង្ឃសូធ្យបាលីគាថា **ពុទ្ធជយមង្គល** គឺធមិ

---

១-បទធម្មប្បដិយោគ ធមិយោគា និងបទផ្ចាញ់មារ ទាំង ២ សង្កាត់នេះជាពាក្យកាព្យសម្រាយ. ពុទ្ធបរិស័ទច្រើនតែនិមន្តសាមណេរតូចៗពីររូបមានសំឡេងពិរោះ ដែលចេះសូធ្យបទទាំង ២ បែបនេះ ឱ្យសូធ្យតាំងពីដើមរហូតដល់ចប់ ។ បើគេសាមណេរប្រភេទនោះពុំបានទេ គេអញ្ជើញបុរសគ្រហស្ថ ២ នាក់មានសំឡេងពិរោះ ដែលធ្លាប់សូធ្យបទនោះ ឱ្យសូធ្យក៏បាន តាមគួរដល់ការលៃលក ។ ចំពោះត្រង់បទផ្ចាញ់មារ. បើមានមធុបាយាសដែលត្រូវថ្វាយព្រះ. កាលបើដល់ពេលអរុណបញ្ចេញស្មើភ្លឺស្រាងៗ គេឱ្យសូធ្យត្រង់ឃ្លាពាក្យកាព្យថា "អណ្ដាប់នោះណា នាងស្រីសុជាតា ថ្វាយមធុបាយាស សឹងគ្រឿងទិព្វតន់ ពេញទាំងភាជន៍មាស ទើបនាងអង្គាស ថ្វាយព្រះទសពល" សូធ្យបីដងៗដែលៗ ។ គេថ្វាយមធុបាយាសជិណាលនឹងវេលាកំពុងសូធ្យនេះ ។ (តាមលំអានរឿង គួរថ្វាយមធុបាយាសពីព្រលឹម, លុះដល់ពេលយប់សឹមធ្វើពិធីពុទ្ធាភិសេក) ។

**ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ ។បេ។ មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ ។** រួចសូធ្យ **មហាការុណិកោ នាថោ ។បេ។ ហោតុ តេ ជយមង្គលំ ។** រួចសូធ្យ **តេ អត្ថលទ្ធា សុខិតា ។បេ។ សហ សព្វេហិ ញាតិភិ ។** បន្ទាប់ពីនេះ ជូនកាលក៏សូធ្យ **ភវតុ សព្វមង្គលំ ។បេ។ សព្វសង្ឃានុភាវេន សទា សោត្ថី ភវន្តុ តេ ។ សង្កាត់ទី ៨**- ពុទ្ធបរិស័ទបាចសាចផ្កាស្រស់ៗ មានផ្កាម្លិះជាដើមទៅលើព្រះពុទ្ធរូបអង្គថ្មី, អ្នកខ្លះមានសុគន្ធវារី ក៏ជជុះរលាស់ទឹកក្រអូបនោះថ្វាយព្រះពុទ្ធរូបអង្គថ្មី ដោយស្ងៀមៗ ឥតបញ្ចេញវាចាថាអ្វី, ជួនកាលកំពុងធ្វើពិធីនេះ អាចារ្យម្នាក់បញ្ចេញវាចាឮខ្លាំងៗ ឱ្យពុទ្ធបរិស័ទថាតាមទាំងអស់គ្នាថា **ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ! មារមានបាបចាញ់ព្រះអង្គហើយ !** (ថា ៣ ដង) ។ **សង្កាត់ទី ៩**- លុះចប់ពិធីនេះហើយ, ពុទ្ធបរិស័ទជាឧបាសកឧបាសិកាទាំងអស់គ្នា សូធ្យធម៌នមស្ការព្រះរត្នត្រ័យ តាមទម្លាប់ដែលតែសូធ្យរៀងមក, រួចហើយសូធ្យធម៌ឧទ្ទិសកុសលផលបុណ្យតាមទម្លាប់ដូចសព្វដង ។ ក៏សន្មតថាចប់ពិធីពុទ្ធាភិសេកមធ្យមត្រឹមប៉ុណ្ណេះ ។

**ពិធីពុទ្ធាភិសេកសង្ខេប**- ជាពិធីខ្លី ។ ខ្ញុំរៀបរៀងពិធីខ្លីនេះ ទុកជារបៀបឱ្យពុទ្ធបរិស័ទអ្នកត្រូវការធ្វើពិធីពុទ្ធាភិសេកសង្ខេប ។ ពិធីសង្ខេបនេះមានត្រឹមតែការរៀបតាក់តែងគ្រឿងសក្ការៈបូជាដោយផ្កាស្រស់ៗ និង

ទៀនធូបថ្វាយព្រះពុទ្ធរូបអង្គថ្មីប៉ុណ្ណោះ-រួចហើយត្រូវនិមន្តព្រះធម្មកថិក សម្តែងរឿង **បឋមត្រាស់** តាមគួរដល់វេលាឬមិនបាច់មានទេសនាបឋម-ត្រាស់ក៏បាន មិនបាច់មានការសូធ្យបាលី **ពុទ្ធាភិសេក** ក៏បាន, ត្រូវនិមន្តព្រះភិក្ខុសង្ឃ ៤ អង្គឬច្រើនអង្គជាងនេះ សុំឱ្យលោកស្វាធ្យាយបាលីតាមលំដាប់ទៅ ។ នៅទីចប់បាលីទាំងអស់ មានប្រែជាសម្រាយថ្វាយសេចក្តីតាមលំអានបាលី សម្រាប់ឱ្យដឹងដំណើររឿងនៃអភិសម្ពោធិក្នុងពិធីពុទ្ធាភិសេកសង្ខេបប៉ុណ្ណោះ ។ ព្រះភិក្ខុសង្ឃត្រូវការសូធ្យសម្រាយនោះផងក៏បាន មិនបាច់សូធ្យក៏បាន ព្រោះសម្រាយនៅខាងចុងដោយឡែកទេ ។ (ត្រូវមើលលេខរៀងតាមលំដាប់) ។

## ព្រះភិក្ខុសង្ឃត្រូវស្វាធ្យាយថា:

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស(១) ។

តស្មឹ សមយេ ពោធិសត្តោ ពោធិរុក្ខក្ខន្ធំ បិដ្ឋិតោ

កត្វា បុរត្ថាភិមុខោ ទឡ្ហមានសោ ហុត្វា

កាមំ តចោ នហារូ ច អដ្ឋិ ច អវសិស្សតុ

សព្វំបិ ហិនំ សរីរេ មំសលោហិតំ ឧបសុស្សតុ

ឥធេវ សម្មាសម្ពោធឹ អប្បត្វា ឥមំ បល្លង្កំ ន

ភិន្ទិស្សាមីតិ អសនិសតសន្និបាតេនាបិ អភេជ្ជរូបំ

អបរាជិតំ បល្លង្កំ អាភុជិត្វា និសីទិ[២] ។

តតោ មហាបុរិសោ អនុលោមប្បដិលោមំ បដិច្ចសមុប្បាទំ មនសាកាសិ :

អវិជ្ជាបច្ចយា សង្ខារា, សង្ខារប្បច្ចយា វិញ្ញាណំ, វិញ្ញាណប្បច្ចយា នាមរូបំ, នាមរូបប្បច្ចយា សឡាយតនំ, សឡាយតនប្បច្ចយា ផស្សោ, ផស្សប្បច្ចយា វេទនា, វេទនាបច្ចយា តណ្ហា, តណ្ហាបច្ចយា ឧបាទានំ, ឧបាទានប្បច្ចយា ភវោ, ភវប្បច្ចយា ជាតិ, ជាតិប្បច្ចយា ជរាមរណំ សោក-បរិទេវ-ទុក្ខ-ទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ[៣] ។

អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ, សង្ខារនិរោធា វិញ្ញាណនិរោធោ, វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ, សឡាយតននិរោធា ផស្សនិរោធោ, ផស្សនិរោធា វេទនានិរោធោ, វេទនានិរោធា តណ្ហានិរោធោ, តណ្ហានិរោធា ឧបាទាននិរោធោ, ឧបាទាននិរោធា ភវនិរោធោ, ភវនិរោធា ជាតិនិរោធោ, ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខ-

ទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ[៤] ។

មហាបុរិសោ ឯតមត្ថំ វិទិត្វា តទនន្តរេ យថាក្កមំ តយោ វារេ ឧទានានិ ឧទានេសិ ៖

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មន្តិ[៥] ។
យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វបយន្តិ សព្វា
យតោ ខយំ បច្ចយានំ អវេទីតិ[៦] ។
យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
វិធូបយំ តិដ្ឋតិ មារសេនំ
សុរិយោវ ឱភាសយមន្តលិក្ខន្តិ[៧] ។

តតោ មហាបុរិសោ‿បូរិតបារមីនំ ពោធិសត្តានំ

អភិសម្ពុជ្ឈនទិវសេ បល្លង្កោ មយ្ហំ បាបុណាតីតិ វត្វា ឋិតំ មារំ អាហ មារ តុយ្ហំ ទានស្ស ទិន្នភាវេ កោ សក្ខីតិ[៨] ។ មារោ ឥមេ ឯត្តកា សក្ខិនោតិ មារគណាភិមុខំ ហត្ថំ បសារេសិ[៩] ។ តស្មិំ ខណេ មារបរិសាយ អហំ សក្ខិ អហំ សក្ខីតិ បវត្ត សទ្ទោ បឋវីឧទ្រិយនសទ្ទសទិសោ អហោសិ[១០] ។ អថ មារោ មហាបុរិសំ អាហ សិទ្ធត្ថ តុយ្ហំ ទានស្ស ទិន្នភាវេ កោ សក្ខីតិ[១១] ។ មហាបុរិសោ តុយ្ហំ តាវ ទានស្ស ទិន្នភាវេ សចេតនា សក្ខិនោ មយ្ហំ បន ឥមស្មិំ ឋានេ សចេតនោ កោចិ សក្ខី នាម នត្ថិ តិដ្ឋតុ តាវ មេ អវសេសត្តភាវេសុ ទិន្នទានំ វេស្សន្តរត្តភាវេ បន ឋត្វា សត្តសតកមហាទានស្ស តាវ ទិន្នភាវេ អយំ អចេតនាបិ មហាបឋវី សក្ខីតិ ចីវរគព្ភន្តរតោ ទក្ខិណហត្ថំ អភិនីហរិត្វា វេស្សន្តរត្តភាវេ ឋត្វា មយ្ហំ សត្តសតកមហាទានស្ស ទិន្នភាវេ ត្វំ សក្ខី ន សក្ខីតិ មហាបឋវ្យាភិមុខំ ហត្ថំ បសារេសិ[១២] ។ មហាបឋវី អហន្តេ តទា សក្ខីតិ វិរាវសតេន វិរាវសហស្សេន មារពលំ អវត្ថរមានា វិយ ឧន្នាទិនី អហោសិ[១៣] ។ តតោ មហាបឋវី ទិន្នន្តេ សិទ្ធត្ថ

មហានាទំ ឧត្តមនាទន្តិ[១៤] ។ វេស្សន្តរត្តភាវេន ទិន្នទានំ សម្ភុសន្តេ សម្ភសន្តេ ទិយឌ្ឍយោជនសតិកោ គិរិមេខលហត្ថី ជន្នុកេហិ បតិដ្ឋាសិ[១៥] ។ មារបរិសា ទិសាវិទិសា បលាយិ[១៦] ។ ទ្វេ ឯកមគ្គេន គតា នាម នត្ថិ[១៧] ។ សីសាភរណានិ ចេវ និវត្ថវសនានិ ច បហាយ សម្មុខសម្មុខា ទិសាហិយេវ បលាយិំសុ[១៨] ។ តតោ ទេវសង្ឃា បលាយមានំ មារពលំ ទិស្វា មារស្ស បរាជយោ ជាតោ សិទ្ធត្ថមហាបុរិសស្ស ជយោ ជយបូជំ ករិស្សាមាតិ នាគា នាគានំ សុបណ្ណា សុបណ្ណានំ ទេវតា ទេវតានំ ព្រហ្មានោ ព្រហ្មានំ ឧគ្ឃោសេត្វា វិជ្ជាធរា គន្ធមាលាទិហត្ថា មហាបុរិសស្ស សន្តិកំ ពោធិបល្លង្កំ អាគមិំសុ[១៩] ។

ឥច្ចេវំ បន វេទិតព្វំ :

"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !
មារស្ស ច បាបិមតោ បរាជយោ !"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !
មារស្ស ច បាបិមតោ បរាជយោ !"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
សុបណ្ណសង្ឃាបិ ជយំ មហេសិនោ ។
"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !
មារស្ស ច បាបិមតោ បរាជយោ !"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ទេវគណា មហេសិនោ ។
"ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !
មារស្ស ច បាបិមតោ បរាជយោ !"
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ព្រហ្មគណាបិ តាទិនោ[២០] ។

មហាបុរិសោ បន ទសសហស្សីលោកធាតុំ ឧន្នាទេន្តោ អរុណុគ្គមនវេលាយ សព្វញ្ញុតញ្ញាណំ បដិវិជ្ឈិ[២១] ។ ឯវំ អបរិមាណេន សិរីវិភវេន បូជិយមានោ នានប្បការេសុ អច្ឆរិយធម្មេសុ បាតុភូតេសុ សព្វញ្ញុតំ បដិវិជ្ឈិត្វា សព្វពុទ្ធានំ អវិជ្ជហិតំ ឧទានំ ឧទានេសិ[២២] :

**អនេកជាតិសំសារំ　　សន្ធាវិស្សំ អនិព្វិសំ**
**គហការំ គវេសន្តោ　　ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ　　បុនគេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ　　តណ្ហានំ ខយមជ្ឈគាតិ**[២៣] ៚

## ប្រែជាសម្រាយ

តាមលំដាប់ **នយលក្ខណៈ** លេខយោងតាំងពីលេខ ១ រៀងដល់ លេខ ២៣ តទៅនេះ :

១- សូមនមស្ការ ចំពោះព្រះភគវ័ត គឺព្រះមានបុណ្យ មានសិរីជោគជ័យ ជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។ ២-ក្នុងសម័យនោះ ព្រះពោធិសត្វទ្រង់បែរព្រះប្រឹស្តាង្គ គឺខ្នងព្រះអង្គ ទៅរកដើមពោធិព្រឹក្សឆ្ពោះព្រះភក្ត្រទៅខាងទិសបូព៌ា ទ្រង់តាំងព្រះហឫទ័យយ៉ាងមុឹងម៉ាត់ថា "ស្បែកក្តី សរសៃក្តី ឆ្អឹងក្តី (បើត្រូវស្ងួតក្រៀម) ក៏ចូរស្ងួតក្រៀមចុះ, ទោះសាច់និងឈាមទាំងអស់ក្នុងសរីរៈរាង្គកាយនេះក៏ដោយ (បើត្រូវរីងស្ងួត) ក៏ចូររីងស្ងួតទៅចុះ, បើអាត្មាអញពុំបានដល់នូវសម្មាសម្ពោធិក្នុងទីនេះទេ, អាត្មាអញនឹងមិនទម្លាយរំសាយភ្នែននេះឡើយ" ហើយព្រះអង្គពែននូវ

អបរាជិតបល្ល័ង្ក គឺព្រះភ្នែនមានជ័យ មានសភាពនឹងធឹង ដែលអ្នកណាមួយឬអ្វីមួយនឹងទម្លាយពុំបាន, ទ្រង់គង់យ៉ាងនឹងធឹងឥតកម្រើក, ប្រសិនបើវន្ទះទាំងរយបាញ់ប្រជុំគ្នាមក ក៏ព្រះអង្គឥតស្ទើបរំភើបឡើយ ។ ៣-លំដាប់នោះ ព្រះមហាបុរស ទ្រង់រំពឹងពិចារណានូវបដិច្ចសមុប្បាទ ជាអនុលោមនិងបដិលោមថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជា គឺមោហៈងងឹតល្ងង់ជាបច្ច័យឱ្យកើត, វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យឱ្យកើត, នាមធម៌និងរូបធម៌កើតមាន ព្រោះវិញ្ញាណជាបច្ច័យឱ្យកើត, អាយតនៈ ៦ កើតមាន ព្រោះនាមធម៌និងរូបធម៌ជាបច្ច័យឱ្យកើត, ផស្សៈកើតមាន ព្រោះអាយតនៈ ៦ ជាបច្ច័យឱ្យកើត, វេទនាកើតមាន ព្រោះផស្សៈជាបច្ច័យឱ្យកើត, តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យឱ្យកើត, ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យឱ្យកើត, ភពកើតមាន ព្រោះឧបាទានជាបច្ច័យឱ្យកើត, ជាតិគឺកំណើតកើតមាន ព្រោះភពជាបច្ច័យឱ្យកើត, ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យឱ្យកើត (កាលបើបដិច្ចសមុប្បាទជាសម្ភវធម៌ទាំង ១២ នេះនៅមាន), សេចក្ដីសោកស្ដាយអាល័យ-ការយំខ្សឹកខ្សួល-សេចក្ដីលំបាកកាយ-ទោមនស្សតូចចិត្ត និងឧបាយាសៈ គឺសេចក្ដីចង្អៀតតានតឹងចិត្ត ក៏តែងតែកើតមានឡើងផងដែរ ។ ការកើតឡើងនៃកងទុក្ខទាំងអស់នេះនៅតែមាន (ព្រោះមានធម៌ជាបច្ច័យទាក់ទងគ្នានាំឱ្យកើត) យ៉ាងនេះឯង (ពុំមែនជាទេព្រៅ

ពីនេះឡើយ) ។ ៤-កាលបើអវិជ្ជារលត់សូន្យ ជាវិរាគធម៌ ឥតសេសសល់ ហើយ សង្ខារក៏រលត់, សង្ខាររលត់ វិញ្ញាណក៏រលត់, វិញ្ញាណរលត់នាមធម៌ និងរូបធម៌ក៏រលត់, នាមធម៌និងរូបធម៌រលត់ អាយតនៈ ៦ ក៏រលត់, អាយតនៈ ៦ រលត់ ផស្សៈក៏រលត់, ផស្សៈរលត់ វេទនាក៏រលត់, វេទនារលត់ តណ្ហាក៏រលត់, តណ្ហារលត់ ឧបាទានក៏រលត់, ឧបាទានរលត់ ភពក៏រលត់, ភពក៏រលត់ ជាតិក៏រលត់, ជាតិរលត់ ជរានិងមរណៈក៏រលត់ (កាលបើបដិច្ចសមុប្បាទទាំង ១២ នោះជានិរោធធម៌រលត់អស់ហើយ), សេចក្តីសោកស្តាយអាល័យ-ការយំខ្សឹកខ្សួល-សេចក្តីលំបាកកាយ-ទោមនស្សតូចចិត្តនិងឧបាយាសៈ គឺសេចក្តីចង្អៀតចង្អល់តឹងចិត្តក៏រលត់ផងដែរ ។ ការរលត់នៃកងទុក្ខទាំងអស់នេះមាន (តៗ គ្នា ព្រោះអស់មានធម៌ជាបច្ច័យនាំឱ្យកើតតទៅទៀត) យ៉ាងនេះឯង (ពុំមែនដទៃក្រៅពីនេះឡើយ) ។ ៥-ព្រះមហាបុរស ទ្រង់ជ្រាបនូវបដិច្ចសមុប្បាទនុះហើយ ព្រះអង្គបន្លឺនូវព្រះឧទានវាចាទាំងឡាយ អស់វារៈ ៣ ដង តាមលំដាប់មុនក្រោយក្នុងចន្លោះៗ នៃការរំពឹងពិចារណានូវបដិច្ចសមុប្បាទនោះថា កាលណាបើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដ ដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅសព្វ អ្នកដុតបំផ្លាញកិលេស, កាលណោះឯង សេចក្តីសង្ស័យទាំងអស់នៃខីណាសវព្រាហ្មណ៍នោះ ក៏បាត់សូន្យអស់ទៅ ព្រោះខីណាសវព្រាហ្មណ៍នោះ ដឹងច្បាស់

នូវធម៌ព្រមទាំងហេតុ គឺចតុរារិយសច្ចធម៌មានទុក្ខសច្ចជាដើម ។ ៦-កាល ណាបើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដ ដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅសព្វ អ្នកដុត បំផ្លាញកិលេស, កាលណោះឯង សេចក្តីសង្ស័យទាំងអស់ នៃខីណាសវ-ព្រាហ្មណ៍នោះ ក៏បាត់សូន្យអស់ទៅ ព្រោះខីណាសវព្រាហ្មណ៍នោះ បានដឹង នូវការអស់នៃធម៌ជាបច្ច័យទាំងឡាយ ។ ៧- កាលណាបើពោធិបក្ខិយធម៌ និងចតុរារិយសច្ចធម៌ទាំងឡាយ កើតមានប្រាកដដល់ខីណាសវព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឱ្យក្តៅសព្វ អ្នកដុតបំផ្លាញកិលេស, (កាល ណោះឯង ខីណាសវព្រាហ្មណ៍នោះ) កម្ចាត់បង់នូវមារនិងសេនាមារបាន (ក៏ភ្លឺស្វាង) ដូចជាព្រះអាទិត្យញ៉ាំងអាកាសឱ្យភ្លឺច្បាស់ ដូច្នោះឯង ។

(**យទា** **ហវេ** ទាំង ៣ គាថានេះជាព្រះឧទានវាចានៃ មហាបុរស ។ ក្នុងគម្ពីរមានប្រាប់សេចក្តីថា ព្រះមហាបុរសទ្រង់បន្លឺព្រះ ឧទានវាចានេះ ក្នុងចន្លោះនិងចន្លោះនៃការពិចារណាបដិច្ចសមុប្បាទធម៌ ជាអនុលោមបដិលោមសាចុះសាឡើងច្រើនដងច្រើនសា ។ ដោយហេតុ នេះ បើពុទ្ធបរិស័ទអ្នកធ្វើពិធីពុទ្ធាភិសេកសង្ខេប មិនគិតពីពេលវែងខ្លីទេ, គួរនិមន្តព្រះភិក្ខុសង្ឃសុំឱ្យលោកស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌មួយចប់ រួចស្វាធ្យាយបាលីគាថា **យទា ហវេ បាតុភវន្តិ ធម្មា ១បេ១ យតោ បជានាតិ សហេតុធម្មំ ១** រួចស្វាធ្យាយបាលីបដិច្ច-

សមុប្បាទធម៌មួយចប់ទៀត, ហើយស្វាធ្យាយ **យទា ហវេ បាតុភវន្តិ ធម្មា ។ បេ ។ យតោ ខយំ បច្ចយានំ អវេទិ ។** រួចស្វាធ្យាយបាលីបដិច្ចសមុប្បាទធម៌មួយចប់ទៀត ហើយស្វាធ្យាយ **យទា ហវេ បាតុភវន្តិ ធម្មា ។ បេ ។ សុរិយោវ ឱភាសមន្តលិក្ខំ ។** បើស្វាធ្យាយតាមន័យនេះ ឃើញថាស្វាធ្យាយបាលីបដិច្ចសមុប្បាទ ៣ ចប់ **យទា ហវេ** ក៏ ៣ ចប់ដែរ គឺស្វាធ្យាយឆ្លាស់គ្នាក្នុងចន្លោះ១) ។

៨- គ្រានោះ ព្រះមហាបុរសទ្រង់មានព្រះបន្ទូលថា "បល្ល័ង្ក (ដែលកើតឡើង) ក្នុងថ្ងៃនៃការត្រាស់ដឹងនៃពោធិសត្វទាំងឡាយ ដែលបានបំពេញបារមីហើយ, ត្រូវបានមកអញ". ហើយព្រះអង្គមានព្រះបន្ទូលទៅរកទេវបុត្តមារដែលឋិតនៅ (ក្នុងទីនោះ) ថា "នៃមារ, អ្នកណាជាសាក្សីក្នុងភារៈនៃទានដែលអ្នកឯងបានឱ្យហើយ?" ។ ៩-ទេវបុត្តមារលាដៃចង្អុលអាងទៅរកពពួករេហ៍ពលថា "ពពួករេហ៍ពលទាំងអម្បាលនេះសុទ្ធតែជាសាក្សី" ។ ១០- ខណៈនោះ សូរស័ព្ទសម្ដីនៃមារបរិស័ទ ក៏លាន់ឮកងរំពងរញ្ជួយឡើងថា "ខ្ញុំជាសាក្សី ! ខ្ញុំជាសាក្សី !" សូរស័ព្ទនោះបាក់ដូចជាសូរស្រុតចុះនៃមហាប្រឹថពី ។ ១១- លំដាប់នោះ ទេវបុត្តមារសួរព្រះមហាបុរសថា "នៃសិទ្ធត្ថ, អ្នកណាជាសាក្សីក្នុងភារៈនៃទានដែលអ្នកឯងបានឱ្យហើយ?" ។ ១២- ព្រះមហាបុរសទ្រង់ឆ្លើយថា "អ្នកឯងអាងសាក្សីដែលមានចេតនា ក្នុងភារៈនៃទានដែលអ្នកឯងបានឱ្យហើយ, ចំណែកខាងអញ,

ក្នុងទីនេះ, ឥតមានអ្នកណាមួយដែលមានចេតនា ជាសាក្សីអញទេ, ទាន ដែលអញបានឱ្យហើយ ក្នុងអត្តភាពដ៏សេសទាំងឡាយ ចូរលើកទុកចុះ (កុំបាច់យកមកនិយាយរះរាងឡើយ), និយាយតែត្រឹម **សត្តសតក-មហាទាន** ដែលកាលអញឋិតនៅក្នុងអត្តភាពជាស្តេចវេស្សន្តរប៉ុណ្ណោះក៏បានហើយ, មហាប្រឹថពីដែលគ្មានចេតនានេះជាសាក្សីរបស់អញ" -ចុះព្រះអង្គឆ្លើយតបយ៉ាងនេះហើយ, ទ្រង់បញ្ចេញព្រះហស្តខាងស្តាំពីក្នុងចន្លោះផ្ទៃនៃចីពរ (ដែលព្រះអង្គឃ្លុំស្រេចស្រាប់ពីនាយមក), ទ្រង់សំយុងព្រះហស្តចង្អុលឆ្ពោះទៅរកមហាប្រឹថពី ដោយបញ្ជាក់ការណ៍ថា "កាលដែលអញឯងឋិតនៅក្នុងអត្តភាពជាស្តេចវេស្សន្តរ អញបានឱ្យ សត្តសតក-មហាទាន តើមហាប្រឹថពីឯងជាសាក្សីមែនឬទេ?" ។ ១៣- ស្រាប់តែមហាប្រឹថពីបញ្ចេញសូរស័ព្ទលាន់ឮខ្ទរខ្ទាំង ហាក់ដូចជាសន្ធាប់គំរាមរហើពលមារ ដោយសូរសម្រែកសន្ធាប់រាប់រយរាប់ពាន់ឡើងថា "ក្នុងកាលណោះខ្ញុំម្ចាស់ជាសាក្សីរបស់ព្រះអង្គ !" ។

(មហាប្រឹថពីនេះបញ្ចេញសូរស័ព្ទដោយសម្តែងអាការជាស្ត្រី, ដោយហេតុនេះឯង បានជាបោរាណាចារ្យហៅមហាប្រឹថពីដែលមានសភាពជាមហាស្ថាវ្យក្នុងគ្រាឆ្លើយអាងថាជាសាក្សីនៃព្រះមហាបុរសនោះថា "នាងធរណី", អ្នកខ្លះហៅតាមទម្លាប់ត១ គ្នាមកថា "នាងគង្ហីងព្រះធរណី") ។

១៤- មិនត្រឹមតែបញ្ចេញសំអាងជាសាក្សីប៉ុណ្ណោះឡើយ, មហា-

ប្រឹថពីថែមទាំងឆ្លើយឡើងទៀតថា "បពិត្រព្រះសុទ្ធត្ថ, មហាទានដែលព្រះអង្គបានឱ្យហើយ ជាទានដ៏ឧត្តម" ។ ១៥- កាលដែលព្រះមហាបុរសទ្រង់ពិចារណាហើយពិចារណាទៀតរឿយៗ នូវទានដែលកាលព្រះអង្គជាស្តេចវេស្សន្តរទ្រង់បានឱ្យហើយ (ជាមហាទានដ៏ឧត្តមនោះ), ក៏ស្រាប់តែដំរីឈ្មោះ **គិរិមេខលៈ** មានកំពស់មួយរយហាសិបយោជន៍ (ជាជំនិះទេវបុត្តមារនោះ) ស្ទុតលុតជង្គង់ស្រុប ។ ១៦- មារបរិស័ទ គឺពួករេហ៍ពលរបស់ទេវបុត្តមារ ក៏រត់ប្រសាចទៅតាមទិសទីទៃៗ ។ ១៧- ពីរនាក់រត់ទៅតាមផ្លូវជាមួយគ្នា ពុំមានសោះឡើយ គឺរត់ទៅតាមផ្លូវដោយខ្លួនៗពីគ្នា ។ ១៨- រេហ៍ពលមារទាំងនោះ បោះបង់គ្រឿងប្រដាប់ដែលពាក់នូវក្បាល និងគ្រឿងស្លៀកពាក់ រត់ប្រសាចទៅតាមទិសទីទាំងឡាយ ដែលចំមុខៗ រៀងរាល់ខ្លួន ។ ១៩- លំដាប់នោះ ពួកទេពតាទាំងឡាយ បានឃើញរេហ៍ពលមារកំពុងរត់ប្រសាចរប៉ាត់រប៉ាយដូច្នោះ ក៏ដឹងច្បាស់ថា "បរាជ័យបានទៅទេវបុត្តមារ, ជ័យជម្នះបានមកព្រះសិទ្ធត្ថមហាបុរស, ពួកយើងនឹងទៅធ្វើជយបូជា ចំពោះព្រះអង្គ" ក៏បញ្ចេញឧត្ឃោសនាការព្ខ្ទាំងរំពងឡើង, គឺពួកនាគស្រែកប្រាប់នាគផងគ្នា, ពួកគ្រុឌស្រែកប្រាប់គ្រុឌផងគ្នា, ពួកទេពតាស្រែកប្រាប់ទេពតាផងគ្នា, ពួកព្រហ្មស្រែកប្រាប់ព្រហ្មផងគ្នា, ពួកពិទ្យាធរស្រែកប្រាប់ពិទ្យាធរផងគ្នា សុទ្ធសឹងតែអោនហត្ថាកាន់គ្រឿងបូជាម៉ានគន្ធមាលាជាដើម មូលគ្នាមកកាន់ពោធិបល្ល័ង្ក

ព័ទ្ធជិតជុំវិញព្រះមហាបុរស ។ ២០- គួរពុទ្ធបរិស័ទជ្រាបថា នៅពេលដែលទេវនិកាយមូលមកស្រែកទ្រហឹងអឹងកង ថ្វាយពរថ្វាយជ័យបូជាចំពោះព្រះមហាបុរសនោះ ព្រះអដ្ឋកថាចារ្យលោកចងក្រងបាលី ៤ គាថានេះសម្រាប់ស្វាធ្យាយក្នុងពិធីពុទ្ធាភិសេក រំលឹកដល់រឿងដែលព្រះមហាបុរសបានសម្រេច អនុត្តរសម្មាសម្ពោធ ។ ខ្ញុំប្រែចំពោះតែត្រង់ជយឃោសថា **ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ ! មារស្ស ច បាបិមតោ បរាជយោ !** "ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ ! មារមានបាបទាល់ព្រះអង្គហើយ !" -ខ្ញុំប្រែតែត្រឹមប៉ុណ្ណេះសម្រាប់ឱ្យពុទ្ធបរិស័ទបន្លឺជយឃោសនេះ ថ្វាយសាធុការពរចំពោះព្រះពុទ្ធរូបអង្គថ្មី ក្នុងពិធីពុទ្ធាភិសេក ។ ២១- ឯព្រះមហាបុរសទ្រង់ញុំាងលោកធាតុទាំងមួយម៉ឺនឱ្យកក្រើករំពើកហើយ, លុះដល់វេលាអរុណនៃថ្ងៃ ១ រោចខែពិសាខជិតរះ, ព្រះអង្គក៏បានត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណ ។ ២២-ព្រះសព្វញ្ញុពុទ្ធ, កាលដែលទេវនិកាយថ្វាយជយឃោសនិងគ្រឿងបូជា ដោយសិរីវិភព គឺសម្បត្តិដ៏មានសិរីប្រមាណពុំបានយ៉ាងនេះ, កាលដែលអច្ឆរិយធម៌ទាំងឡាយមានប្រការផ្សេងៗ កើតមានប្រាកដឡើងហើយ, ព្រះអង្គក៏បានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ, ហើយទ្រង់បន្លឺនូវព្រះឧទានវាចាដែលព្រះពុទ្ធគ្រប់ព្រះអង្គ, (ទើបបានត្រាស់ភ្លាមៗ) ទ្រង់ពុំដែលបោះបង់ គឺព្រះអង្គពុំដែលខានបន្លឺសោះឡើយ ។ ២៣- (ព្រះអង្គបន្លឺព្រះវាចាញ

ខ្លាំងៗ ដោយសោមនស្សចំពោះសព្វញ្ញុតញ្ញាណ, ប្រាស្រ័យទៅរកតណ្ហា ជាអរូបធម៌ ហាក់ដូចជាគេនិយាយទៅរកមនុស្សផងគ្នា ។ ខ្ញុំប្រែសម្រួលសេចក្ដីឱ្យពុទ្ធបរិស័ទអ្នកមិនចេះប្រែបាលីងាយស្ដាប់ងាយយល់) ។ ព្រះអង្គបន្លឺថា "នែតណ្ហា ! អ្នកឯងជាមេជាងសាងសង់រូបរាងសព៌ាង្គកាយ អញតថាគត ដូចជាមេជាងដែលសង់ផ្ទះជាលំនៅទូទៅដូច្នោះដែរ, អញតថាគតអន្ទោលកើតស្លាប់ ស្លាប់កើតក្នុងវាលវដ្ដសំសារ ជាអនេកជាតិរាប់មិនអស់ ពីព្រោះតែតណ្ហាឯងហ្នឹងជាអ្នកសាងសង់, អញតថាគតខំប្រឹងស្វះស្វែងរកឱ្យជួបនឹងជាងផ្ទះឯងនេះ អស់កាលយូរអង្វែងណាស់ហើយតើ! ចេះតែឃ្លាង មិនជួបប្រទះអ្នកឯងហ្នឹងសោះ (ព្រោះអ្នកឯងប៉ិនគេចវេះ ប៉ិនលាក់មុខ លាក់ខ្លួនណាស់ !), (នែជាតិ !), ជាតិឯងនេះ (ជាសំណង់របស់តណ្ហា) ចេះតែនាំយកទុក្ខព្រួយលំបាកមកផ្ដុករឿយៗ ឱ្យអញតថាគត, នែជាងផ្ទះ ! (ឥឡូវ) អញតថាគតបានជួបប្រទះឃើញអ្នកឯងហើយ, អ្នកឯងនឹងសង់ផ្ទះទៀតលែងកើតហើយ, ឆ្អឹងជំនីរទាំងអស់ (ដែលទុកដូចជាគ្រឿងទព្វសម្ភារៈសម្រាប់សង់ផ្ទះ) របស់អ្នកឯង អញតថាគតបានរុះរើបំបាក់ខ្ទេចខ្ទីអស់ហើយ, កំពូលផ្ទះ របស់អ្នកឯង) អញតថាគតបានរះរើបោះគ្រវែងចោលខ្ទេចខ្ទីល្អិតល្អន់អស់ហើយ

បានឡើងដល់ថ្នាក់វិសង្ខារ រួចផុតស្រឡះចាកសំណង់ថ្មីទៀត (របស់ជាងផ្ទះឯង) ហើយ, ចិត្តអញតថាគតបានដល់នូវ តណ្ហក្ខ័យ ឈប់លែង

ចូលដៃ សមគំនិត ស៊ុមគ្រលុំងអឺតងងល់ ជាមួយនឹងជាងផ្ទះឯងហ្នឹងតទៅទៀតហើយ ' " ។

---

លុះព្រះភិក្ខុសង្ឃស្វាធ្យាយបាលីឧទានគាថានេះចប់ហើយ, លោកអាចារ្យគ្រហស្ថម្នាក់សូធ្យឱ្យអ្នកទាំងអស់ថាតាមព្រមៗ គ្នាថា :

**ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ !** "**ព្រះពុទ្ធមានសិរីទ្រង់ឈ្នះហើយ**" **មារស្ស ច បាបិមតោ បរាជយោ !** "**មារមានបាបចាញ់ព្រះអង្គហើយ !**" **៣** សូធ្យឱ្យថាតាមព្រមៗ គ្នាបីដង ។ សូធ្យបណ្ដើរ បាចសាចសុគន្ធបូជាបណ្ដើរ ។ បន្ទាប់មក ពុទ្ធបរិស័ទសូធ្យធម៌នមស្ការព្រះរត្នត្រ័យ ដូចទម្លាប់សព្វដង ។ សន្មតថា ចប់ពិធីពុទ្ធាភិសេកសង្ខេបត្រឹមតែប៉ុណ្ណោះ ។

# ពិធីចម្អិននិងការថ្វាយមធុបាយាស

◆◆◆◆◆◆◆◆

បើពុទ្ធបរិស័ទត្រូវការធ្វើពិធីពុទ្ធាភិសេកពិស្តារ ជាពិសេសប្លែកពីពិធីដែលធ្លាប់ធ្វើរៀងមកនោះ ត្រូវធ្វើអស់រយៈកាល **បីថ្ងៃ** គឺថ្ងៃ ១៤ កើត ១៥ កើត និង ថ្ងៃ ១ រោចនៃខែពិសាខ តាមតែក្នុងឆ្នាំណាក៏ដោយ ។

នៅវេលារសៀលនៃថ្ងៃ ១៤ កើត ត្រូវរៀបចំគ្រឿងពុទ្ធបូជាចំពោះព្រះពុទ្ធរូបអង្គថ្មី, ត្រូវធ្វើព្រះរាជវ័តខ្នាតតូច ២ ម៉ែត្រ ៤ ជ្រុងស្មើ នៅលើទីដីដ៏ស្អាត មិនឆ្ងាយប៉ុន្មានពីទីតម្កល់ព្រះពុទ្ធរូបអង្គថ្មីនោះ ដោយមានទង់និងឆត្រូច ដែលធ្វើដោយក្រដាសពណ៌ផ្សេងៗ ដោតដង្ហែជុំវិញព្រះរាជវ័តិនោះ មានចង្ក្រានចំកណ្ដាលព្រះរាជវ័តិ និងខ្ទះស្ពាន់ឬខ្ទះដែកជំទើរមួយ ហើយនិងឈ្មួងសម្រាប់ដុតចម្អិនមធុបាយាស កុំឱ្យមានផ្សែងដូចដុតអុស ។ នៅវេលាយប់ ១៤ កើតនោះ, ចាប់តាំងពីម៉ោង ២០ ទៅដល់ម៉ោង ៣, ស្ត្រីចាស់ក្មេងច្រើននាក់ នាំគ្នាបកគ្រាប់ស្រូវដំណើបឱ្យបានជាអង្ករ កុំឱ្យមានបាក់សូម្បីមួយគ្រាប់ ឱ្យបានចំនួនល្មមដល់ការចម្អិនមធុបាយាសគោត, ប្រសិនបើពូតជាពំនូតៗ ល្មមពមកើត ឱ្យបានចំនួន ៤៩ ពំនូត ។ លុះដល់វេលាម៉ោង ៤ នៃយប់ ១៤ កើតនោះ, ស្ត្រីទាំងអស់នាំគ្នាផ្សំគ្រឿង ដោយមានទឹកដោះគោកំប៉ុង, ស្ករគ្រាប់ ឬស្ករសក៏បាន, ស្ករអំពៅបន្ទះៗ ត្រូវយកកាំបិតស្អាតចិតឱ្យល្អិត, ទឹកឃ្មុំ, គ្រាប់ក្រវាញដែលបុកល្អិតផង់ និង

ផ្លែដីប៊ីក្រៀមដែលបុកល្អិតផង់ដែរ. (ផង់គ្រាប់ក្រវាញនិងផង់ផ្លែដីប៊ីទាំង ២ មុខនេះ យកតែបន្តិចៗ កុំឱ្យច្រើនហួសប្រមាណ), ឱ្យមានអំបិលផង តែបន្តិចបានហើយ ។ ត្រូវយកគ្រឿងទាំងអស់នេះផ្សំជាមួយនឹងអង្ករដំណើបដែលបកហើយនោះ ដាក់ក្នុងខ្ទះហើយ លាយទឹកឱ្យល្មមមធុបាយាសនោះឡើងខាប់. កាលបើឆ្អិនស្រេចហើយឱ្យល្មមពូតជាពំនូតបាន ។ ការចម្អិននេះ ត្រូវឱ្យនាងកញ្ញា ២ នាក់ជាអ្នកចម្អិន, ឱ្យកូរបង្វិលជាទក្ខិណាព័តិ គឺកូរឱ្យវិលស្តាំទៅឆ្វេង (ដូចគេដើរប្រទក្សិណអ្វីៗ ដែរ) ។ ត្រូវកូរបណ្តើរមើលថែភ្លើងបណ្តើរ កុំឱ្យភ្លើងដែលដុតចង្ក្រានោះឆេះខ្លាំង គឺត្រូវបន្ថយភ្លើងជាដរាប ។ ត្រូវចម្អិនដោយប្រយ័ត្នជានិច្ច កុំឱ្យមធុបាយាសនោះមានក្លិនឆ្អៀមឬខ្លោច ។ នៅពេលកំពុងចម្អិននោះ ត្រូវមានបុរស ៤ នាក់ ដែលតែងខ្លួនធ្វើជាលោកបាលមហារាជទាំង ៤ ដើរប្រទក្សិណក្រឡឹងជុំវិញព្រះរាជវ័តិ. ដើរក្រឡឹងច្រើនបកច្រើនសា ត្រាតែមធុបាយាសនោះឆ្អិនស្រេចដោយប្រពៃ ។ លុះមធុបាយាសនោះឆ្អិនស្រេចហើយ. នៅពេលដែលអរុណ ១៥ កើត ខែពិសាខរះភ្លឺច្បាស់, នាងកញ្ញាទាំង ២នាក់នោះដួសដោះមធុបាយាសដាក់ក្នុងចានគ្របពិសេស ហើយតម្កល់ចានលើតោកទីបមាសឬតោកដាំខ្សងឬក៏ដាំកញ្ចក់, ពុំនោះ ទោះតម្កល់លើពានជំទើរក៏បាន, ប្រសិនបើមានចានមាសឬចានប្រាក់កាឡៃមាស ក៏ជាការប្រពៃណាស់ សមនឹងលំអានរឿងថា "ភាជន៍មាស" ពុំចាំបាច់តម្កល់លើតោកឬ

តានជំទើរឡើយ ។ ត្រូវនាងកញ្ញាម្នាក់ទូលមធុបាយាសដើរមុន (សន្មត នាងនេះថា នាងសុជាតាបុត្រីនៃសេនកុដុម្ពិកនៅសេនានិគម ឧរុវេលា). នាងកញ្ញាម្នាក់ទៀតដើរក្រោយបន្ទាប់គ្នា ឥតទូលឬកាន់អ្វីទេ (សន្មតនាង នេះថា នាងបុណ្ណា ជាទាសីនៃនាងសុជាតា) ។ កញ្ញាទាំង ២ នាក់នេះដើរ សំរៀម១ មិនរលេះរលាំងទេ ។ ស្ត្រីទាំងអស់ក្រៅពីកញ្ញាទាំង ២ នាក់ នោះ ត្រូវដើរហែពីក្រោយ ឱ្យឃ្លាតឆ្ងាយបន្តិច ។ លុះកញ្ញាទាំង ២ នាក់ បានមកដល់ទីតម្កល់ព្រះពុទ្ធរូបអង្គថ្មី, ក៏ដាក់មធុបាយាសចំពោះព្រះភ័ក្ត្រ ព្រះពុទ្ធរូប, លុតជង្គង់ក្រាបថ្វាយបង្គំ ហើយលើកហត្ថាប្រណម្យ បញ្ចេញ វាចាថ្វាយមធុបាយាសថា **ខ្ញុំម្ចាស់សូមថ្វាយមធុបាយាសនេះ ចំពោះ ព្រះភគវ័ត ! សូមព្រះអង្គទ្រង់ទទួលដោយសេចក្ដីអនុគ្រោះ !**

-នេះជាពិធីចម្អិននិងការថ្វាយមធុបាយាស ។

លុះដល់ពេលព្រលប់នៃថ្ងៃ ១៥ កើតខែពិសាខ, ពុទ្ធបរិស័ទត្រូវធ្វើ ពិធីពុទ្ធាភិសេកតាមលំដាប់ទៅ រហូតដល់អរុណោទ័យនៃថ្ងៃ ១ រោច ។ នៅថ្ងៃ ១ រោចខែពិសាខនោះឯង, ពុទ្ធបរិស័ទត្រូវធ្វើពិធីឆ្លងបុណ្យពុទ្ធា-ភិសេក តាមគួរដល់សទ្ធាជ្រះថ្លា, ដោយការអង្គាសចង្ហាន់ព្រឹកនិងថ្ងៃត្រង់ ប្រគេនព្រះភិក្ខុសង្ឃ ជាទក្ខិណាសង្ឃគតាទាន និងការនិមន្តព្រះធម្មកថិក សម្ដែងធម៌ក្នុងថ្ងៃនោះផងទៀតក៏បាន ។

គួរពុទ្ធមាមកជនជ្រាបថា ពិធីបែបនេះ ពុំមែនងាយធ្វើកើតទេ, បើ

បែរជាធ្វើកើត, ក៏ជាបុណ្យកុសលពិសេស គួររីករាយណាស់ ។ ប៉ុន្តែផ្ទុយទៅវិញ, បើពុំបានគិតរិះរេឱ្យហ្មត់ចត់ល្អិត ល្អអំពីចេតនានៃអ្នកធ្វើពិធីបែបនេះទេ, ក៏បែរជារកកល់នឹងយល់ឃើញថា ប្រហែលគ្នាឬដូចគ្នានឹងរឿងល្ខោនឬរឿងភាពយន្តទៅវិញទេដឹង? -ឯតាមការណ៍ពិត, ពុំមែនដូច្នោះសោះឡើយ ព្រោះពិធីពុទ្ធាភិសេកបែបនេះកើតមានឡើងអំពីចេតនាជាកាមាវចរកុសលសុទ្ធសាធ ។ បើពុទ្ធបរិស័ទអាចធ្វើបាន ក៏គួរធ្វើចុះ !

# ការបញ្ជាក់អំពីពិធីដែលពុំគួរធ្វើ

១-កុំយកកន្ត្រៃឬកាំបិតកោរវាសជន្លួហាក់ដូចជាកាត់ព្រះកេសាព្រះ ដ្បិតព្រះពុទ្ធរូបអង្គថ្មីនោះជាងគេសាងរួចសព្វគ្រប់ស្រេចទៅហើយ ។

២-កុំប្រើពិធីបើកព្រះនេត្រព្រះ ដ្បិតព្រះពុទ្ធរូបអង្គថ្មីនោះជាងគេសាងឱ្យមានព្រះនេត្រទាំងពីរស្រេចទៅហើយ ។

៣-កុំយកអំបោះចងព្រះពុទ្ធរូបអង្គចាស់ទាញមកទាក់ភ្ជាប់នឹងព្រះពុទ្ធរូបអង្គថ្មី ដ្បិតអំបោះនោះពុំអាចស្រូបយកបារមីទាំង ៣០ ពីព្រះចាស់មកព្រះថ្មីទេ ។ ការយល់របស់អ្នកខ្លះដែលធ្លាប់តែធ្វើយ៉ាងនោះ លើសពីការណ៍ពិតឆ្ងាយណាស់, ពុំគួរធ្វើដូច្នោះឡើយ ។

៤-ដុតធូបថ្វាយព្រះ ត្រូវដុតថ្វាយដោយគោរព, កុំដុតឱ្យទាល់តែហុយផ្សែងទ្រុបទៅលើព្រះ ។

៥-កុំឱ្យមនុស្សអ្នកក្រមាច់កំប្លែង ឬមនុស្សកំពុងស្រវឹងស្រា តែងខ្លួនធ្វើជាទេវបុត្តមារ មកស្រែកគម្រាមព្រះ ដោយសម្ដែងកាយវិការនិងសម្ដីពុំគោរពទៅរកព្រះឡើយ ។

៦-ពិធីណាក៏ដោយ ដទៃក្រៅពីពិធីឆ្លងខាងលើនេះ កំពុទ្ធបរិស័ទពុំត្រូវធ្វើពិធីនោះឡើយ ដ្បិតថា **ពុទ្ធេ អគារវតា** "ការមិនគោរពចំពោះព្រះពុទ្ធ" ទៅវិញ ។ បើមិនគោរពចំពោះព្រះពុទ្ធហើយ ក៏ឈ្មោះថាមិនគោរពចំពោះព្រះធម៌និងព្រះសង្ឃដែរ ។ (គួរយើងគោរពឱ្យសមឋានៈជាពុទ្ធសាសនិកជន) ។

## ជ.ណ. ជោតញ្ញាណោ

## សង្ឃរាជា

## ~ចប់~